ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

លេខ ១៨៣/២២ គ.ជ.ប.ជ

# របាយការណ៍ឆមាសទី១
# ស្ដីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងទិសដៅអនុវត្តបន្តឆមាសទី២ ឆ្នាំ២០២២

## I. ស្ថានភាពទូទៅ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត បានបន្តសកម្មភាព របស់ខ្លួនទៅតាមទិសដៅគ្រោងទុក។ ទន្ទឹមនឹងនោះ សភាពការណ៍សកលលោក មានការវិវត្តន៍ប្រែប្រួលថ្មីៗ ប្លែកៗ គួរឲ្យកត់សម្គាល់ និងមិនអាចប៉ាន់ស្មានបាន ដែលមានទាំងវិបត្តិសេដ្ឋកិច្ច សង្គ្រាមរ៉ាំរ៉ៃនៅបណ្ដាប្រទេសមួយចំនួន គ្រោះធម្មជាតិ(ទឹកជំនន់ ខ្យល់ព្យុះ ខ្យល់កន្ត្រាក់ បំណាក់ដី ភ្លើងឆេះព្រៃ...) និងថែមទាំងគ្រោះមហន្តរាយដោយការរាតត្បាតនៃវីរុសកូវីដ-១៩ និងមេរោគបំប្លែងថ្មី។ វិបត្តិនៃផលប៉ះពាល់ដោយ ជំងឺកូវីដ-១៩ មិនទាន់បានបញ្ចប់ផង ក៏មានព្រឹត្តិការណ៍ដ៏អាក្រក់ជាច្រើនទៀតកើតឡើងជាបន្តបន្ទាប់ថែមទៀត ក្នុងឆ្នាំ២០២២ នេះ ដែលរួមទាំងការផ្ទុះសង្គ្រាមរវាងប្រទេសដែលនៅជិតខាងគ្នានៅក្នុងទ្វីបអឺរ៉ុប គឺសង្គ្រាមរុស្ស៊ី និងអ៊ុយក្រែន បានជះឥទ្ធិពលអវិជ្ជមាន រីឯ បរិស្ថាន និងអាកាសធាតុ ប្រែប្រួលខុសពីធម្មតា គួរឲ្យបារម្ភ និងប៉ះពាល់ដល់ការរស់នៅរបស់មនុស្សសត្វលើផែនដី ធ្វើឲ្យប្រទេសជាច្រើន រងនូវវិបត្តិសេដ្ឋកិច្ច និងសង្គមជាសាកល។

ឆ្លៀតក្នុងស្ថានភាពដ៏ប្រឈមនេះ ក្រុមទុច្ចរិត និងបណ្ដាញរបស់ខ្លួន បានព្យាយាមរកគ្រប់មធ្យោបាយ បង្កើតនូវបទល្មើសថ្មីៗ ព្រមជាមួយនឹងការប្រើប្រាស់បច្ចេកវិទ្យាទំនើប សម្រាប់ទាក់ទាញជនរងគ្រោះ ឲ្យធ្លាក់ចូលក្នុងកលល្បិចទុច្ចរិត ដើម្បីបម្រើមហិច្ឆតារបស់ខ្លួន ដែលបង្កឲ្យមានផលប៉ះពាល់យ៉ាងធំធេង លើជនរងគ្រោះទាំងក្នុង និងក្រៅប្រទេស។

រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងតែ យកចិត្តទុកដាក់យ៉ាងខ្លាំង លើកិច្ចការពារអាយុជីវិតប្រជាពលរដ្ឋដែលបង្កដោយការរាតត្បាតដ៏ខ្លាំងក្លានៃវីរុសកូវីដ-១៩ និងផលប៉ះពាល់ដល់សេដ្ឋកិច្ច សង្គម ដ៏ធំធេង និងខិតខំការពារសន្តិសុខ ក្នុងប្រទេស និងក្នុងតំបន់ ខិតខំរកដំណោះស្រាយបញ្ហាដោយទន់ភ្លន់បញ្ចៀសការប្រឈមមុខដាក់គ្នា និងការពារភាពរឹងមាំនៃចំណងសាមគ្គីភាព និងកិច្ចសហការក្នុងតំបន់ ដាក់ស្តែងជោគជ័យនៃការដោះស្រាយបញ្ហាតំបន់ក្នុងពេលដែលព្រះរាជាណាចក្រកម្ពុជា ធ្វើជាប្រធានអាស៊ានក្នុងឆ្នាំ២០២២នេះ។

ទន្ទឹមនឹងកិច្ចខិតខំប្រឹងប្រែងដ៏ច្រើនសន្ធឹកសន្ធាប់ ក្នុងការដោះស្រាយភាពប្រឈមដែលជះឥទ្ធិពលជាអវិជ្ជមានដល់ជីវភាពប្រជាពលរដ្ឋ និងបង្កភាពរាំងស្ទះដល់ការអនុវត្តសកម្មភាពអភិវឌ្ឍន៍គ្រប់វិស័យ រាជរដ្ឋាភិបាលកម្ពុជា ដែលមានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាសេនាធិការ នៅគ្រប់កម្រិត បានរៀបចំយុទ្ធសាស្ត្រ និងដាក់ចេញនូវវិធានការចម្បងៗជាច្រើន រាប់ទាំងការកសាងច្បាប់ គោលនយោបាយ បទដ្ឋានគតិយុត្តនានា ដើម្បីការពារប្រជាពលរដ្ឋពីភាពរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ចនានា។ ក្នុងស្ថានភាពដ៏ អាក្រក់នៃភាពប្រឈមនឹងការស្វែងរកការងារនៅក្រៅប្រទេសដោយប្រថុយប្រថាន ក្នុងឋានៈជាពលករមិនស្របច្បាប់ រាជរដ្ឋាភិបាល

កម្ពុជា តែងស្វះស្វែងរកដំណោះស្រាយជាមួយប្រទេសពាក់ព័ន្ធ ដើម្បីកាត់បន្ថយភាពងាយរងគ្រោះ និងលើកកម្ពស់សុវត្ថិភាពពលករចំណាកស្រុក ព្រមទាំងដោះស្រាយភាពប្រឈមរបស់ពលករវិលត្រឡប់រាប់សិបម៉ឺននាក់ និងប្រជាពលរដ្ឋក្នុងស្រុកដែលប្រឈមនឹងវិបត្តិកូវីដ-១៩ តាមរយៈការដាក់ចេញនូវគោលនយោបាយសន្តិសុខសង្គម យ៉ាងទូលំទូលាយ ដើម្បីបង្ការទប់ស្កាត់ភាពទ័លច្រក និងប្រថុយប្រថានរបស់ប្រជាពលរដ្ឋ ក្នុងការជឿលើការអូសទាញរបស់មេខ្យល់ ឬឧក្រិដ្ឋជនឲ្យធ្លាក់ក្នុងភាពរងគ្រោះ។

ថ្មីៗនេះ មិនត្រឹមតែប្រជាជនកម្ពុជាទេ តែប្រជាជននៃប្រទេសដទៃក្នុងតំបន់ រហូតដល់ពីបណ្តាប្រទេសធំៗក្នុងពិភពលោក ក៏បានធ្លាក់ក្នុងភាពរងគ្រោះដោយកលល្បិចឧក្រិដ្ឋជន។ បញ្ហាជួញដូរមនុស្ស បានក្លាយជាវិបត្តិសាកល ដែលស្ទើរតែគ្រប់ប្រទេសក្នុងសាកលលោកកំពុងប្រឈម ដោះស្រាយ និងកាន់តែស្មុគ្រស្មាញខ្លាំងឡើង។

ប្រជាជនយើង មួយចំនួននៅតែមើលស្រាលស្ថានភាព មិនស្តាប់ការអប់រំណែនាំ មិនតាមដានព័ត៌មានដែលមានប្រយោជន៍ តែបែរជាស្តាប់ និងជឿការអូសទាញ ភូតភរពីមេខ្យល់ ធ្វើឲ្យពួកគាត់ធ្លាក់ទៅក្នុងអំពើជួញដូរមនុស្ស និងខាតបង់ទាំងទ្រព្យសម្បត្តិ និងកម្លាំងកាយ រហូតដល់ធ្លាក់ខ្លួនឈឺដ៏ធ្ងន់ធ្ងរថែមទៀត។

ក្នុងរយៈពេល៦ខែ ដើមឆ្នាំ២០២២ គ្រប់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ក្នុងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅគ្រប់កម្រិត និងមានការចូលរួមគាំទ្រសហការ ដោយអង្គការដៃគូជាតិ និងអន្តរជាតិពាក់ព័ន្ធ បានបន្តធ្វើសកម្មភាព ប្រតិបត្តិការ តាមយុទ្ធសាស្ត្រដែលបានកំណត់ ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារ ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

#### ១. ការកសាងច្បាប់

- ក្រសួងយុត្តិធម៌ បានរៀបចំ៖
  - -បន្តពិនិត្យសេចក្តីព្រាងច្បាប់ ស្តីពី «ការប្រឆាំងអំពើរត់ពន្ធមនុស្ស» និងច្បាប់ស្តីពី «អំពើពពោះជំនួស»។
  - -សេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសប៊ែលហ្សិក ប៉េរូ និងប្រទេសឡាវ ស្តីពី «ការបញ្ជូនទណ្ឌិត»។
  - -សន្ធិសញ្ញា ស្តីពី បត្យាប័ន ជាមួយប្រទេសឥណ្ឌា និងប្រទេសបេឡារូស។
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បាន និងកំពុងសិក្សារៀបចំសេចក្តីព្រាងច្បាប់ ស្តីពី «ទេសន្តរប្រវេសន៍ការងារកម្ពុជានៅបរទេស»។

#### ២. សន្ធិសញ្ញា

- ក្រសួងយុត្តិធម៌
  - -បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសឡាវ បារាំង និងប្រទេសកូរ៉េខាងត្បូង ស្តីពី "ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ"
  - -បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសអង់គ្លេស ប៉េរូ និងប្រទេសឡាវ ស្តីពី "ការបញ្ជូនទណ្ឌិត"។

#### ៣. គោលនយោបាយ និងអនុស្សរណៈនៃការយោគយល់គ្នា

- គណៈកម្មាការធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានចុះអនុស្សរណៈនៃការយោគយល់គ្នា ចំនួន ០៣ គឺជាមួយ៖
  - -អង្គការការីតាស្វីស ស្តីពី «ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរាល់ទម្រង់នៃការកេងប្រវ័ញ្ចក្នុងការធ្វើចំណាកស្រុក ឆ្នាំ២០២២-២០២៤»។

-**អង្គការ Erikshjalpen** ស្តីពីសកម្មភាពបង្ការ ទប់ស្កាត់ប្រយុទ្ធប្រឆាំងរាល់ទម្រង់នៃការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចលើកុមារ (ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២២)។

-**អង្គការ វីនរ៉ក់អន្តរជាតិ** ដើម្បីរួមចំណែកលើកកម្ពស់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងបង្កើនប្រសិទ្ធភាពវិធានការប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា (ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២)។

## ៤. លិខិតបទដ្ឋានគតិយុត្ត

- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖ បានរៀបចំកិច្ចប្រជុំពិនិត្យលើសេចក្តីព្រាងប្រកាស ស្តីពីលក្ខខណ្ឌការងារកុមារ ក្នុងមុខរបរផលិតកម្មអំពៅចំនួន ០៣លើក នៅថ្ងៃទី៧ និងថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២២ និងថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២។

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖** ធ្វើសេចក្តីព្រាងរៀបចំអនុក្រឹត្យ ស្តីពីបែបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។

- **ក្រសួងកិច្ចការនារី** បានរៀបចំសេចក្តីព្រាង៖

-វិសោធនកម្មអនុស្សរណៈនៃការយោគយល់ ស្តីពី កិច្ចសហប្រតិបត្តិការប្រឆាំងការជួញដូរ មនុស្សនៅមហាអនុតំបន់មេគង្គ(COMMIT)។

-យន្តការបញ្ជូនឆ្លងដែនមានលក្ខណៈស្តង់ដារួមគ្នាតែមួយ និងរួមទាំងចាត់តាំងគ្រូបង្គោល របស់ប្រទេសជាសមាជិកខមមីត(COMMIT)នីមួយៗ។

-អនុស្សរណៈនៃការយោគយល់គ្នា រវាងក្រសួងកិច្ចការនារី និងអង្គការសម្ព័ន្ធចាប់ដៃ ក្នុងគោលបំណងពង្រឹង: ១-ការប្រឹក្សាយោបល់ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទនៅ តាមសហគមន៍។ ២-កិច្ចសហប្រតិបត្តិការជាមួយអង្គការដៃគូ ក្នុង និងក្រៅប្រទេស ក្នុងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះ។ ៣-ការផ្តល់សេវាផ្នែកច្បាប់ដល់ជនរងគ្រោះដោយអពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទ ជាពិសេសស្ត្រី និងកុមារ។

- **ក្រសួងអប់រំយុវជន និងកីឡា៖** បានរៀបចំពិធីប្រកាសឱ្យអនុវត្តផ្លូវការនូវសៀវភៅណែនាំប្រតិបត្តិ ស្តីពីកិច្ចការពារកុមារនៅក្នុងសាលារៀន។
- **ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍៖** បានរៀបចំបង្កើតសេចក្តីណែនាំដល់ប្រតិបត្តិករទូរគមនាគមន៍ និងបច្ចេកវិទ្យា គមនាគមន៍និងព័ត៌មាន អោយបន្តចូលរួមក្នុងសកម្មភាពទប់ស្កាត់ និងការពារកុមារលើប្រព័ន្ធអនឡាញ ព្រមទាំងទប់ស្កាត់ហានិភ័យការរំលោភបំពានផ្លូវភេទតាមប្រព័ន្ធអនឡាញ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ

- **គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** បានរៀបចំកិច្ចប្រជុំ៖

-ជាមួយសមាជិកគណៈកម្មាធិការ និងមន្ត្រីជំនាញពីតាមបណ្តាក្រសួង ស្ថាប័ន រាជធានី ខេត្ត និងអង្គការដៃគូជាតិ និងអន្តរជាតិ ស្តីពី «ការពិនិត្យឡើងវិញនូវ លទ្ធផលការងារ ភាពប្រឈម» (២០១៩-២០២១) និងគំនិតផ្តួចផ្តើមសម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្របន្ត(២០២២-២០២៣) តាមប្រព័ន្ធអនឡាញ។

-ជាច្រើនលើក តាមប្រព័ន្ធអនឡាញ ជាមួយអង្គការសហប្រជាជាតិទទួលបន្ទុកការងារទេសន្តប្រវេសន៍នៅទីក្រុងហ្សឺណែវ បណ្តាញអង្គការទេសន្តប្រវេសន៍ របស់អង្គការសហប្រជាជាតិប្រចាំតំបន់ អគ្គលេខាធិការដ្ឋានអាស៊ាន និងជាមួយអន្តរក្រសួង ស្ថាប័ន ក្នុងការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងនាមជាប្រទេសជ័យលាភីក្នុងការអនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់។

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បាន៖

-បំពេញបេសកកម្មនៅប្រទេសថៃ ចាប់ពីថ្ងៃទី១ ខែមីនា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ ដើម្បីតម្លើងសម្ភារ និងប្រព័ន្ធតភ្ជាប់ ជូនស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំព្រះរាជាណាចក្រ

ថៃឡង់ដ៍ សម្រាប់មន្ត្រីស្ថានទូតប្រើប្រាស់ និងដាក់ឱ្យដំណើរការនូវប្រព័ន្ធបន្តសុពលភាពបណ្ណ OCWC និងលិខិតធ្វើដំណើរ TD។

- ដឹកនាំកិច្ចប្រជុំរបស់ក្រុមការងារស្នូលកម្ពុជានៃក្រុមការងារមហាអនុតំបន់មេគង្គស្តីពីទេសន្តរប្រវេសន៍ការងារ (GMS Task Force on Labour Migration) ជាមួយអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២២ ដើម្បីត្រៀមរៀបចំវេទិកា ស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់បណ្តាប្រទេសក្នុងតំបន់ GMS។
- បានរៀបចំកិច្ចប្រជុំពិនិត្យលើសេចក្តីព្រាងប្រកាស ស្តីពីលក្ខខណ្ឌការងារកុមារក្នុងមុខរបរផលិតកម្មអំពៅចំនួន៣លើក នៅថ្ងៃទី៧-១៩ ខែកុម្ភៈ ឆ្នាំ២០២២ និងថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២

▪ **ក្រសួងកិច្ចការនារី៖** បានសហការជាមួយអង្គការ UN Women រៀបចំកិច្ចប្រជុំជាមួយក្រុមការងារសហប្រតិបត្តិការអន្តរជាតិ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងក្រុមការងារខមមីតកម្ពុជា នៅសណ្ឋាគារហ៊ីម៉ាវ៉ារី ក្នុងគោលបំណង: **១**-ពិនិត្យលើវឌ្ឍភាព ទម្រង់ថ្មីៗ និងបញ្ហាប្រឈមនៃអំពើជួញដូរមនុស្សនៅកម្ពុជា។ **២**-ការស្វែងយល់ពីអនុសញ្ញា CEDAW ទៅនឹងគោលនយោបាយជាតិ ដែលឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រីពលករទេសន្តរប្រវេសន៍។ **៣**-ប្រមូលធាតុចូលដើម្បីរៀបចំផែនការរបស់ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ និងក្រុមការងារខមមីតកម្ពុជា ឆ្នាំ២០២២-២០២៣ ដែលមានអ្នកចូលរួមពីក្រសួង ស្ថាប័ន និងអង្គការមិនមែនរដ្ឋាភិបាលសរុបចំនួន ៤៧នាក់(ស្រី ២១នាក់)។

## ខ. ការបង្ការ ទប់ស្កាត់

### ១. តាមរយៈការលើកកម្ពស់ការយល់ដឹង

#### ១.១ .ការផ្សព្វផ្សាយដោយផ្ទាល់

| ការផ្សព្វផ្សាយដោយផ្ទាល់ | ចំនួនលើក | ចំនួនអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|
| កិច្ចប្រជុំ និងវេទិកាផ្សព្វផ្សាយជាសាធារណៈ | ៥២.៨០២ | ២.៣១២.៧៧៣ | ១.២០០.៦២២ |
| តាមរយៈកម្មវិធីផ្សេងៗ ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ | ៤៨ | ២៧.១៦០ | ៩.៩០៨ |
| អង្គការដៃគូ | ២២ | ៣.១០៤ | ១.៦៥៥ |
| **សរុប** | **៥២.៨៧២លើក** | **២.៣៤៣.០៣៧នាក់** | **១.២១២.១៨៣នាក់** |

១.១.១. កិច្ចប្រជុំ និងវេទិកាផ្សព្វផ្សាយជាសាធារណៈ

នៅក្នុងឆមាសទី១ ឆ្នាំ២០២២នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ ការអនុវត្តគោលនយោបាយ "**ភូមិ-ឃុំ មានសុវត្ថិភាព**" និងកម្មវិធីផ្សេងៗ ដល់មន្ត្រីរាជការ សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ សាសនិកជន និងប្រជាពលរដ្ឋ សរុបចំនួន **៥២.៨០២**លើក មានអ្នកចូលរួមសរុបចំនួន **២.៣១២.៧៧៣**នាក់ (ធៀបនឹងឆមាសទី១ ឆ្នាំ២០២១ មានចំនួន **២.២៨១.០២១**នាក់) គឺមានការកើនឡើងចំនួន **៣១.៧៥២**នាក់ ស្មើនឹង **១,៣៩%** ក្នុងនោះស្ត្រីចំនួន **១.២០០.៦៦២**នាក់។ ដូចមានតារាងលម្អិតខាងក្រោម៖

**តារាងទិន្នន័យការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ និងវេទិកាសាធារណៈ**

| ល.រ | ក្រសួង ស្ថាប័ន | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | រាជធានី-ខេត្ត | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| ក្រសួង ស្ថាប័ន | | | | | | | |
| ១ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ០៤ | ១.១០៣ | ១៦២ | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ៣០០ | ២៨.៨១៦ | ១៥.៤២១ | ២៦១ | ១២.៩២៣ | ៦.៧០៨ |
| សរុប ក្រសួង ស្ថាប័ន | | **៣០៤ លើក** | **២៩.៩១៩ នាក់** | **១៥.៥៨៣ នាក់** | **២៦១នាក់** | **១២.៩២៣នាក់** | **៦.៧០៨នាក់** |
| **រាជធានី-ខេត្ត** | | | | | | | |
| ១ | រាជធានីភ្នំពេញ | | | | ២ | ២៤០ | ១២២ |
| ២ | ខេត្តកណ្តាល | ៤.៤៣០ | ១៧០.៦៥៩ | ៩៩.៥២៤ | ៥.៨០១ | ៣១០.៧១៩ | ១៦១.៣០៧ |
| ៣ | ខេត្តបាត់ដំបង | ៣.៥៦១ | ១៤៨.០៦៣ | ៦៨.៨៤៧ | ២.៣៤៨ | ៧៣.៣៥៧ | ៣៨.៩០៩ |
| ៤ | ខេត្តពោធិ៍សាត់ | ២.៧៦៦ | ២៤៦,៧៤៥ | ១៣៨.០៦៣ | ២៧៨ | ២៥.៧៧៩ | ១២.២៨០ |
| ៥ | ខេត្តសៀមរាប | ៥២៦ | ២៩.៨០៥ | ១៧.៣០២ | | | |
| ៦ | ខេត្តកំពង់ឆ្នាំង | ៥.៣៧២ | ១៣៧.៩៩៩ | ៧០.២១៤ | ២.៨៨៨ | ៥១.៥៨៨ | ២៧.៨៣៥ |
| ៧ | ខេត្តកំពង់ចាម | ១១.២០០ | ៦៣៩.១៧៧ | ៣៣៩.០៩៤ | ៦.៧៤៧ | ១៩៥.៧១៦ | ១០១.៤៣៩ |
| ៨ | ខេត្តព្រះសីហនុ | ៧ | ៣៦៤ | ២០៥ | | | |
| ៩ | ខេត្តព្រះវិហារ | ៥៥ | ៦.០៨៣ | ៣.៩៧០ | ១២ | ៥២៨ | ៣២៤ |
| ១០ | ខេត្តស្វាយរៀង | ១.៦៤៧ | ៥០.៧៧៥ | ១៤.៩០២ | ០៣ | ៧៥៨ | ៣៣៨ |
| ១១ | ខេត្តប៉ៃលិន | ៥៤៥ | ១០.៩៤០ | ៣.០២៣ | ២៦៦ | ១០.៦៤០ | ៣.៣៨៣ |
| ១២ | ខេត្តកោះកុង | ៣៦ | ៨១៣ | ៤៥៧ | ២៤៧ | ៥.០៩៦ | ២.៥៣៦ |
| ១៣ | ខេត្តកំពត | ៧៩ | ២.២០៧ | ១.៣៤៨ | ៣០ | ១.០៦៩ | ៦៧៣ |
| ១៤ | ខេត្តកំពង់ធំ | ៩០ | ៦.៩០១ | ៤.៩១៩ | | | |
| ១៥ | ខេត្តតាកែវ | ១.៦២៤ | ៥៣.០៤៩ | ២៥.៦៦៨ | ៥៥៤ | ១៧.៦២២ | ៨.៤១៨ |
| ១៦ | ខេត្តក្រចេះ | ៩៤ | ៤.៦៤៧ | ២.២១៨ | | | |
| ១៧ | ខេត្តកែប | ១៣០ | ២៣.៥៣៣ | ៩.៩៩៣ | ១៩៣ | ៨.១៦៣ | ៤.០៣២ |
| ១៨ | ខេត្តកំពង់ស្ពឺ | | | | | | |
| ១៩ | ខេត្តស្ទឹងត្រែង | ០១ | ៩១ | ៦៣ | ០១ | ១៣៣ | ៩៩ |
| ២០ | ខេត្តរតនគិរី | ៥៩ | ២.៩៥៥ | ១.៣៥១ | | | |
| ២១ | ខេត្តព្រៃវែង | ៣១៦ | ១៨.០៧៩ | ៨.៨២៦ | ១៣ | ២.១០៣ | ៣៣៧ |
| ២២ | ខេត្តត្បូងឃ្មុំ | ១០ | ៥.៤៤៣ | ២.៨០១ | | | |
| ២៣ | ខេត្តបន្ទាយមានជ័យ | ៤៩ | ១.៩៥៦ | ៣២៥ | ០៣ | ៥៤៣ | ២៧៧ |
| ២៤ | ខេត្តឧត្តរមានជ័យ | ០៤ | ១.៨៥៦ | ១.៣១២ | | | |
| ២៥ | ខេត្តមណ្ឌលគិរី | ២៥០ | ៤.២៣៧ | ១៥.៩៧ | | | |
| សរុប រាជធានី-ខេត្ត | | **៣២.៨៥១** | **១.៥៦៦.៣៧៧** | **៨១៦.០២២** | **១៩.៣៨៦** | **៧០៣.៥៥៤** | **៣៦២.៣០៩** |
| សរុបរួម<br>ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត | | ចំនួន<br>៥២.៨០២ លើក | | ចំនួនមនុស្សសរុប<br>២.៣១២.៧៧៣ នាក់ | | ចំនួនស្ត្រី<br>១.២០០.៦៦២ នាក់ | |

### ១.១.២. ការផ្សព្វផ្សាយតាមរយៈកម្មវិធីផ្សេងៗ

- ថ្នាក់ជាតិ
  - គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានរៀបចំពិធីប្រជុំផ្សព្វផ្សាយរបាយការណ៍បូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២១ និងលើកទិសដៅអនុវត្តឆ្នាំ២០២២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ មានអ្នកចូលរួមសរុបប្រមាណ **៣៥០**នាក់(ស្រី **៨២**នាក់) នៅសាលសន្និបាតវិទ្យាស្ថានជាតិអប់រំរាជធានីភ្នំពេញ។

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បាន៖
  - រៀបចំប្រារព្ធពិធីអបអរខួបលើកទី៧៣ ទិវាកុមារអន្តរជាតិ១មិថុនា ខួបលើកទី២១ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា និងទិវាកុមារកម្ពុជា ឆ្នាំ២០២២ ក្រោមប្រធានបទ "កិច្ចគាំពារសង្គមជាសកល ដើម្បីបញ្ចប់ពលកម្មកុមារ" ដែលមានអ្នកចូលរួមសរុបចំនួន **៣២៥**នាក់(ស្រី **៩៥**នាក់) នៅទីស្តីការក្រសួង។
  - សហការជាមួយអង្គការ IOM រៀបចំយុទ្ធនាការណ៍ផ្សព្វផ្សាយពីសេវាការងារក្នុងស្រុក និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព នៅខេត្តបន្ទាយមានជ័យ។
- **ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ៖** បានបញ្ជ្រាបខ្លឹមសារការងារបង្ការ ទប់ស្កាត់រាល់ទម្រង់នៃអំពើជួញដូរមនុស្ស នៅថ្ងៃទិវាវប្បធម៌ជាតិ ក្នុងមហោស្រពសិល្បៈយុវជនទូទាំងប្រទេស ដើម្បីលើកកម្ពស់ការយល់ដឹង ដល់សិស្ស និស្សិត សិល្បៈករ សិល្បៈការិនី និងប្រជាពលរដ្ឋ សរុបចំនួន **៦.៧៦៥**នាក់ (ស្រី **២.៩១៧**នាក់)។
- **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** បានសហការជាមួយ **ក្រសួងអប់រំ យុវជន និងកីឡា** អង្គការ Aple Cambodia និងសហការ ឧបត្ថម្ភដោយអង្គការ Plan International Cambodia អង្គការ UNICEF និងក្រុមហ៊ុន Smart Axiata រៀបចំយុទ្ធនាការគាំទ្រទិវាអន្តរជាតិដើម្បីសុវត្ថិភាពអ៊ីនធឺណិត **"រួមគ្នាលើកកម្ពស់ ការពារ និងគោរពសិទ្ធិកុមារតាមរយៈការប្រើប្រាស់ប្រព័ន្ធអនឡាញប្រកបដោយការទទួលខុសត្រូវ"** ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ អ្នកចូលរួមប្រមាណ **៣៥០**នាក់ នៅវិទ្យាស្ថានជាតិអប់រំ និងបានបន្តផ្សព្វផ្សាយ តាមប្រព័ន្ធអនឡាញ ដល់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស បានប្រមាណ **២៥០**នាក់បន្ថែមទៀត។
- **អង្គការដៃគូ**
  - **អង្គការតំណក់ទឹក៖** បានសហការជាមួយអាជ្ញាធរភូមិ/ឃុំ/សង្កាត់ ខេត្តបន្ទាយមានជ័យ៖
    - ផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ ដើម្បីលើកកម្ពស់នៅក្នុងសហគមន៍ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋនៅក្នុងភូមិ/ឃុំ/សង្កាត់ បានចំនួន **០១**លើក មានអ្នកចូលរួមចំនួន **៤៨៧**នាក់(ស្រី **២៨៤**នាក់)។
    - ផ្សព្វផ្សាយតាមរយៈការចុះធ្វើបណ្ណាល័យចល័ត ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងផ្សព្វផ្សាយពីសេវារបស់អង្គការតំណក់ទឹកនៅតាមសហគមន៍ នៅសង្កាត់ប៉ោយប៉ែត ផ្សារកណ្តាល និងសង្កាត់និមិត្ត បានចំនួន ០២លើក មានអ្នកចូលរួមចំនួន **៥២៦**នាក់(ស្រី **២៤៨**នាក់)។
  - **អង្គការទេសន្តរប្រវេសន៍ (IOM)៖** បានសហការជាមួយរដ្ឋបាលស្រុកពួក និងស្រុកស្វាយលើ ខេត្តសៀមរាប ធ្វើការផ្សព្វផ្សាយអំពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការផ្តល់ការងារជូនពលករចំណាកស្រុក នៅឃុំពួក និងឃុំសំរោងយា ស្រុកពួក និងឃុំស្វាយលើ ស្រុកស្វាយលើ បានចំនួន ០៣លើក មានអ្នកចូលរួមចំនួន **៤២៥**នាក់(ស្រី **១៦៨**នាក់)។
  - **អង្គការបន្ទាយស្រី៖** បានសហការជាមួយរដ្ឋបាលស្រុកអង្គរជុំ ខេត្តសៀមរាប បានរៀបចំកិច្ចប្រជុំជាមួយក្រុមបុរស នៅឃុំដូនពេង គោកដូង គោល នគរភាស ស្រែខ្វាវ និងឃុំតាសោម ស្តីពីកិច្ចការពារកុមារ ដែលចំណាកស្រុកតាមឪពុកម្តាយឱ្យមានសុវត្ថិភាព ដើម្បីគាំទ្រដល់ស្ត្រី និងក្មេងស្រី ០១លើក មានអ្នកចូលរួមចំនួន **៤៥**នាក់(ស្រី ០១នាក់)។
  - **អង្គការមូលនិធិអេ២១៖** បានធ្វើការផ្សព្វផ្សាយដល់សហគមន៍ស្តីពី ការលើកកម្ពស់ការយល់ដឹងអំពីការជួញដូរមនុស្ស ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងកិច្ចការពារកុមារ បានចំនួន **១០**លើក មានអ្នកចូលរួមសរុប **៤៧០**នាក់ (ស្រី **២៥០**នាក់)។

- **អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ(IJM)៖** បានសហការជាមួយស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម រៀបចំវេទិកាសាធារណៈផ្សព្វផ្សាយអប់រំ ស្ដីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងវិធានការទប់ស្កាត់អំពើរំលោភសេពសន្ថវៈ ដល់លោកមេឃុំ លោកនាយ-នាយរង និងមន្ត្រីប៉ុស្តិ៍នគរបាលរដ្ឋបាល និងប្រជាពលរដ្ឋនៅឃុំព្រែកតានង់ ស្រុកស្ទឹងត្រង់ចូលរួម ចំនួន **៧៦**នាក់ (ស្រី **៤៥**នាក់)។
- **អង្គការចាប់ដៃ៖** បានសហការជាមួយស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម ផ្សព្វផ្សាយច្បាប់ ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ដល់អាជ្ញាធរមូលដ្ឋាន នៅសាលាស្រុកស្ទឹងត្រង់ ដែលមានអ្នកចូលរួមសរុប ១៨នាក់ (ស្រី ០៥នាក់)។
- **អង្គការ(CWCC)៖** បានសហការជាមួយអាជ្ញាធរមូលដ្ឋានខេត្តបន្ទាយមានជ័យ ចុះផ្សព្វផ្សាយស្ដីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព មានអ្នកចូលរួមចំនួន **៣២១**នាក់(ស្រី**២០០**នាក់)។
- **អង្គការសកម្មភាពដើម្បីកុមារ APLE** ៖ បានសហការជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប រៀបចំកម្មវិធីលើកកម្ពស់ការយល់ដឹង ស្ដីពីការស្វែងយល់អំពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ចំនួន ០២លើក មានអ្នកចូលរួម **៧៣៦**នាក់ (ស្រី **៤៥៤**នាក់)។

▪ ថ្នាក់ក្រោមជាតិ

- **ខេត្តកំពង់ចាម៖**
  - **រដ្ឋបាលក្រុង ស្រុកទាំង១០៖**បានបញ្ជ្រាបការផ្សព្វផ្សាយទៅតាមរយៈកិច្ចប្រជុំ គ.ស.ន.ក និងគ.ក.ន.ក ពាក់ព័ន្ធទៅនឹងការចាប់រំលោភសេពសន្ថវៈទៅលើស្ត្រី និងកុមារ និងអំពីបញ្ហាចំណាកស្រុកទៅរកការងារធ្វើ ចៀសវាងការឆបោកតាមរយៈមេខ្យល់។
  - **មន្ទីរអប់រំ យុវជន និងកីឡាខេត្តបាន៖** ១-បានចុះផ្សព្វផ្សាយការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ដល់យុវជនទាំង១០ក្រុង ស្រុក ដែលបានមកចូលរួមការបោះជំរំយុវជនថ្នាក់ខេត្ត នៅវិទ្យាល័យ ហ៊ុន សែន ស្តន់ ស្រុកជើងព្រៃ ចំនួន **១៥០**នាក់។ ២-ផ្សព្វផ្សាយដល់សហគមន៍ ស្ដីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស តាមរយៈការចុះពិនិត្យតាមដាន និងការប្រជុំក្រុមឪពុកម្ដាយកុមារតូចអាយុ០ ដល់៣ឆ្នាំ តាមភូមិគោលដៅក្នុងឃុំ និងក្រុង-ស្រុក។ និងបានផ្សព្វផ្សាយដល់សហគមន៍ស្ដីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស តាមរយៈការចុះពិនិត្យតាមដាន ដល់សិស្សដែលរៀនថ្នាក់អក្ខរកម្មវិជ្ជាជីវៈ ថ្នាក់សមមូលបឋមសិក្សា និងថ្នាក់មជ្ឈមណ្ឌលសិក្សា សហគមន៍ តាមភូមិ ឃុំ និងក្រុង-ស្រុក ដែលបានអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធ។
  - **ខេត្តកណ្ដាល** ៖ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត បានបញ្ជ្រាបការផ្សព្វផ្សាយអំពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈការប្រជុំបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡាប្រចាំខែធ្នូ ឆ្នាំ២០២១ និងត្រៀមរៀបចំបើកបវេសមកាលឆ្នាំសិក្សាថ្មី នៅគរុកោសល្យ និងវិក្រឹតការខេត្ត ដែលមានការចូលរួមពី ថ្នាក់ដឹកនាំមន្ទីរ លោកប្រធានការិយាល័យចំណុះមន្ទីរ ប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាល ក្រុង/ស្រុកទាំង១១ លោកស្រីនាយិកាវិទ្យាល័យទូទាំងខេត្ត សរុបចំនួន ៣៣៨នាក់(ស្រី ១៤០នាក់)។
- **ខេត្តបន្ទាយមានជ័យ៖** បានបញ្ជ្រាបការផ្សព្វផ្សាយអប់រំ អំពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈលោកស្រី **រស់ សុផានី** រួមសហការជាមួយមន្ទីរសង្គមកិច្ចបានចុះសួរសុខទុក្ខ រួមនឹងចែកអំណោយដល់ស្ត្រីមានផ្ទៃពោះ និងកុមារនៅមណ្ឌលចត្តាឡីស័កកងវ៉ា ចំនួន **៣១**នាក់។
- **ខេត្តតាកែវ៖** បានបើកវេទិកាថ្នាក់ដឹកនាំ និងកុមារប្រចាំឆ្នាំ២០២២ ក្រោមប្រធានបទផ្សព្វផ្សាយ និងការអនុវត្តច្បាប់លិខិតបទដ្ឋានគតិយុត្តិ ឆ្លើយតបនឹងកិច្ចការពារកុមារ ចំនួន ០១លើក មានអ្នកចូលរួមចំនួន **៩៥**នាក់(ស្រី **៧៥**នាក់)។

- **ខេត្តកែប៖**
  - ឯកឧត្តមបណ្ឌិត **សោម ពិសិដ្ឋ** អភិបាល នៃគណៈអភិបាលខេត្តកែប បានបញ្ជ្រាបផ្សព្វផ្សាយអំពីផលប៉ះពាល់នៃការធ្វើចំណាកស្រុកដោយខុសច្បាប់ ជូនដល់កម្មករ កម្មការនី តាមរយៈការចុះអធិការកិច្ចដល់រោងចក្រកែយ៉ាស៊ីនស៊ូ ចំនួន ០១លើក មានសមាសភាពចូលរួមសរុប ៨០០នាក់ (ស្រី ៦៦៦នាក់)។
  - មន្ទីរអប់រំ យុវជន និងកីឡាខេត្ត បានបញ្ជ្រាបផ្សព្វផ្សាយការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដល់នាយក នាយិកាសាលារៀន និងការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក និងនាយក នាយិកាសាលារៀនបាន តាមរយៈនៅពេលគោរពទង់ជាតិ បានចំនួន ១៥លើក មានលោកគ្រូ អ្នកគ្រូ និងសិស្សចូលរួមសរុបចំនួន ១០.៤៣៤នាក់ (ស្រី ៥.១៩៨នាក់)។
  - មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានបានបញ្ជ្រាបផ្សព្វផ្សាយការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈការចុះអប់រំណែនាំដល់និយោជិត តាមគ្រឹះស្ថានក្នុងខេត្តសរុប **១៤៣** គ្រឹះស្ថាន មានកម្មករនិយោជិតចូលរួមសរុប **១.២៣៩**នាក់ (ស្រី **៥៨៧**នាក់)។
- **ខេត្តបាត់ដំបង៖** លេខាធិការដ្ឋាន គ.ខ.ប.ជ តាមរយៈនិងវិជានការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ បានបញ្ជ្រាបកាផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ឱកាសស្វែងរកការងាររបស់ប្រជាពលរដ្ឋ នៅមណ្ឌលទទួលពលករកំរៀង ស្ថិតនៅស្រុកកំរៀង។
- **ខេត្តសៀមរាប៖**
  - រដ្ឋបាលស្រុកពួក បានរៀបចំយុទ្ធនាការផ្សព្វផ្សាយការប្រើប្រាស់សេវាការងារ តាមប្រព័ន្ធអ៊ីនធឺណិត និងចំណេះដឹងផ្នែកហិរញ្ញវត្ថុ នៃការធ្វើចំណាកស្រុកដោយស្របច្បាប់ បានចំនួន ០១លើក ដែលមានអ្នកចូលរួមសរុប ៦០នាក់ (ស្រី ៣៤នាក់)។
  - មន្ទីរអប់រំ យុវជន និងកីឡាខេត្ត សហការជាមួយសាខាកាកបាទក្រហមកម្ពុជាខេត្ត និងអង្គការ APLE តាមរយៈប្រជុំលើកកម្ពស់ការយល់ដឹងតាមប្រព័ន្ធអនឡាញ និងបានផ្សព្វផ្សាយ ស្តីពីការស្វែងយល់អំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព នៅវិទ្យាល័យខ្នារសណ្តាយ និងវិទ្យាល័យ ហ៊ុន សែន ស្វាយធំ ដល់គណៈកម្មាធិការសាខា អនុសាខា និងគណៈកម្មាធិការប្រតិបត្តិក្រុមប្រឹក្សាកុមារ យុវជន ប្រជាជន និងសិស្ស បានចំនួន **០៦**លើក មានអ្នកចូលរួមសរុប **៦៦៤**នាក់ ស្រី**៣៦៣** នាក់។
  - រដ្ឋបាលស្រុកអង្គរជុំ បានសហការជាមួយអង្គការភ្លែនអន្តរជាតិ រៀបចំកម្មវិធីសម្តែងរឿង ក្រោមប្រធានបទ ផលប៉ះពាល់នៃការរៀបការវ័យក្មេង ដែលសម្តែងដោយក្រុមក្លឹបកុមារ និងយុវជនវិទ្យាល័យដូនពេង ដែលមានអ្នកចូលរួមសរុប ១២៥នាក់។
- **ខេត្តព្រៃវែង៖** បានបញ្ជ្រាបការផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព សុំកុំធ្វើចំណាកស្រុក និងសូមកុំចាញ់បោកល្បិចបោកប្រាស់របស់ជនឆ្លៀតឱកាសមួយចំនួន តាមរយៈ៖
  - ពិធីសម្ពោធឆ្លងសាលាភត្ត និងសមិទ្ធផលនានានៅវត្តជ្រៃឧត្តម ក្រោមអធិបតីភាព ឯកឧត្តម **ជា សុមេធី** អភិបាលខេត្ត ប្រធានគណៈបញ្ជាការឯកភាពខេត្ត និងជាប្រធានគ.ខ.ប.ជ។
  - ការរៀបចំកម្មវិធីអបអរសាទរខួបលើកទី១១១ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២២ ដែលមានអ្នកចូលរួមសរុប **១.៤៤៦**នាក់ (ស្រី **១.២៧៨**នាក់)។
  - ពិធីបុណ្យបញ្ចុះខណ្ឌសីមាវត្តមុនីរតនប្បភា ហៅវត្តថ្មី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជាប្រធាន គ.ជ.ប.ជ** នៅឃុំស្វាយភ្លោះ ស្រុកពាមជរ ដែលមានអ្នកចូលរួមសរុប **៧៦៩**នាក់។
  - ពិធីបុណ្យឆ្លងសមិទ្ធិផលនានា នៅវត្តឧត្តមសារគរ (ហៅវត្តព្រែកក្របៅ) ក្នុងភូមិឧត្តម ឃុំព្រែកក្របៅ ស្រុកពាមជរ ក្រោមអធិបតីភាព ឯកឧត្តម **ជា សុមេធី** អភិបាលខេត្ត និងជាប្រធានគ.ខ.ប.ជ។ ដែលមានអ្នកចូលរួមសរុប **៧៣៨**នាក់។

- **ខេត្តស្វាយរៀង៖** លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំវេទិកាផ្សព្វផ្សាយ អន្តរសាសនាស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្រោមប្រធានបទ " រួមគ្នាបញ្ឈប់ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចលើគ្រប់រូបភាព " ក្រោមអធិបតីភាព លោកជំទាវ **ឯក សុវណ្ណភារៈ** អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ និងព្រះវិសុទ្ធិញាណ **មុំ សយ** ព្រះរាជាគណៈថ្នាក់កិត្តិយស ព្រះមេគណខេត្តស្វាយរៀង និងមានការអញ្ជើញចូលរួម ពីព្រះមន្ត្រីសង្ឃព្រះអនុគណ ព្រះគ្រូចៅអធិការវត្ត លោកគ្រូអាចារ្យវត្ត បូជាចារ្យ គ្រូគង្វាល ថ្នាក់ដឹកនាំនៃគ្រីស្តសាសនា សាសនាមហាយាន ឥស្លាមសាសនា និងបាហៃសាសនា លោក លោកស្រីអភិបាលរងក្រុង ស្រុកទាំង០៨ លោក លោកស្រី កងកម្លាំងទាំង៣ ប្រធាន អនុប្រធាន មន្ទីរពាក់ព័ន្ធនៃក្រុមការងារទាំង៦ និងតំណាងអង្គការដៃគូរ មានចូលរួមចំនួន **២៣១** អង្គ/នាក់ ។
- **ខេត្តកំពង់ឆ្នាំង៖** មន្ទីរអប់រំ យុវជន និងកីឡា បានបញ្ជ្រាបចំណេះដឹងពាក់ព័ន្ធនឹងការជួញដូរមនុស្សតាមរយៈការចុះពិនិត្យថ្នាក់មត្តេយ្យសិក្សាសហគមន៍ ការចុះចងក្រងក្រុមសមាជិកមាតាបិតាថ្មី របស់គម្រោងហ្វ្រើន ការចុះទស្សនកិច្ចសិក្សា ការបើកវគ្គបំប៉នទឹកស្អាត និងអនាម័យ ការដាំបន្លែដល់សាលារៀន ការពិនិត្យតាមដានលើការងារគ្រប់គ្រងដឹកនាំ និងការរៀនបង្រៀនក្នុងឆ្នាំសិក្សា ២០២១-២០២២ និងការពិនិត្យតាមដាន រៀបចំរចនាសម្ព័ន្ធ និងពង្រឹងសមត្ថភាពមេដឹកនាំក្រុមប្រឹក្សាយុវជន កុមារ ចំនួន ០៦លើក។

### ១.១.៣.ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក

- **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ៖**
  - បានសហការជាមួយ **និយ័តករទូរគមនាគមន៍កម្ពុជា (TRC)** ធ្វើការផ្ញើសារអប់រំតាមរយៈទូរស័ព្ទចល័ត នៅថ្ងៃទិវាកុមារអន្តរជាតិ ០១មិថុនា ដែលមានខ្លឹមសារ "រួមគ្នាលុបបំបាត់រាល់ការរំលោភបំពាន និងការកេងប្រវ័ញ្ចលើកុមារ"។
  - បានផ្សព្វផ្សាយព័ត៌មាន និងច្បាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស តាមរយៈផេកហ្វេកប៊ុក មានអ្នកចូលមើលចំនួន ៤៨.៩៤៩នាក់។
- **ខេត្តសៀមរាប៖** មន្ទីរព័ត៌មាន បានធ្វើការផ្សព្វផ្សាយអប់រំ នៅក្នុងកម្មវិធីវិទ្យុជាតិនគរភ្នំ FM103MHz និងទូរទស្សន៍ជាតិខេត្តសៀមរាប ស្តីពីកិច្ចការពារជនរងគ្រោះ វិធានការទប់ស្កាត់ការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអ៊ីនធឺណិត ការស្វែងរកការងារក្នុងស្រុកជាជាងការចំណាកដោយប្រថុយប្រថាន ការស្វែងរកជំនួយពីអាជ្ញាធរ និងអង្គការសង្គមស៊ីវិល ចំនួន **៥០១**លើក (ផ្សាយផ្ទាល់ **១៧១**លើក និងចាក់ផ្សាយឡើងវិញ **៣២៣**លើក)។
- **ខេត្តព្រៃវែង៖** មន្ទីរព័ត៌មាន បានធ្វើការផ្សព្វផ្សាយសារអប់រំតាមវិទ្យុបាពយណ៍អណ្តែត FM-30 MHz ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន **២០៥**លើក ក្នុងមួយថ្ងៃ ០៥លើក។
- **ខេត្តកំពង់ចាម៖** មន្ទីរព័ត៌មានខេត្ត បានផ្សព្វផ្សាយតាមវិទ្យុជាតិភ្នំស្រីភ្នំប្រុស ពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សចំនួន ៨០លើក។
- **ខេត្តតាកែវ៖** មន្ទីរព័ត៌មានខេត្ត បានផ្សព្វផ្សាយ៖
  - ច្បាប់ និងសកម្មភាពនានាពាក់ព័ន្ធនឹងការបង្ក្រាបអំពើជួញដូរមនុស្ស កិច្ចការពារជនរងគ្រោះដោយអំពើជួញដូរ និងការធ្វើអាជីវកម្ម ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការចូលរួមទប់ស្កាត់ជំងឺកូវីដ-១៩ ទូរទស្សន៍ជាតិគោកធ្លក(តាមរយៈស្ថានីយ៍ទូរទស្សន៍ខ្សែកាប្លិ៍ប៉ុស្តិ៍លេខ១៤) សរុបចំនួន **១០.៩១២**អត្ថបទ/លើក។
  - ព័ត៌មានតាមស្ថានីយ៍វិទ្យុFM92.5MHz អំពីសកម្មភាពនានាពាក់ព័ន្ធ ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរ ការធ្វើជីវកម្មផ្លូវភេទ និងផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស សរុបចំនួន **១២.៥៩៨**លើក/អត្ថបទ។

- **ខេត្តកំពង់ឆ្នាំង៖ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត** បានបញ្ជ្រាបចំណេះដឹងពាក់ព័ន្ធនិងការជួញដូរមនុស្ស តាមរយៈការប្រជុំតាមប្រព័ន្ធ Telegram ឬ Google Meet ទៅដល់លោកប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង/ស្រុកទាំង៨ ដើម្បីឱ្យលោកប្រធានការិយាល័យ ធ្វើការផ្សព្វផ្សាយបន្ត ទៅដល់ នាយក នាយិកា សិស្សានុសិស្ស នៅពេលគោរពទង់ជាតិមុនចូលរៀន និងក្នុងម៉ោងសិក្សា ចំពោះមេរៀនដែលពាក់ព័ន្ធ។
- **ខេត្តត្បូងឃ្មុំ៖** បានផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ ស្តីពីភូមិឃុំមានសុវត្ថិភាព និងការអប់រំពីការធ្វើ ចំណាកស្រុកដោយសុវត្ថិភាព ចំនួន ០១លើក។

១.១.៤.ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចូលរួមជាវាគ្មិន៖**
  - ក្នុងកិច្ចពិភាក្សាលើប្រធានបទ "ការផ្សព្វផ្សាយនៃការសិក្សា ស្តីពីផលប៉ះពាល់សេដ្ឋកិច្ចសង្គមនៃ បរិបទកូវីដ-១៩ លើបញ្ហាពលករទេសន្តរប្រវេសន៍នៅកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងប្រទេសថៃ" តាមប្រព័ន្ធអនឡាញ
  - ក្នុងវេទិកា ស្តីពី "មោទនភាពស្ត្រីពលករចំណាកស្រុក" ដែលរៀបចំដោយស្ថានីយវិទ្យុស្ត្រី **១០៣.៥**។
- **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖** ឯកឧត្តម ឧត្តមសេនីយ៍ទោ **កែវ សុវណ្ណារ៉ា** អគ្គលេខាធិការរង និងលោកឧត្តមសេនីយ៍ទោ **រ៉ន សុក័ក្រវឌ្ឍនា** ប្រធានក្រុមជំនួយកិច្ចការ បានអញ្ជើញជាគ្រូបង្គោលធ្វើបទឧទ្ទេសច្បាប់ ដល់សិក្ខាកាមជាកងកម្ទេចគ្រាប់មិនទាន់ផ្ទុះ ដែលត្រៀម ចូលរួមបំពេញបេសកកម្មរក្សាសន្តិភាពរបស់ អ.ស.ប នៅសាធារណរដ្ឋអាហ្វ្រិកកណ្តាល ចំនួន **៤៥**នាក់ (ស្រី ០៥នាក់) នៅសាលាហ្វឹកហ្វឺនបណ្តុះបណ្តាល កងកម្លាំងរក្សាសន្តិភាពពហុជាតិ។
- **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖** ឯកឧត្តមឧត្តមសេនីយ៍ឯក **លី តុងហ៊ុយ** អគ្គលេខាធិការរង និងលោកឧត្តមសេនីយ៍ទោ **សេក ស៊ីវ៉េត** ប្រធានក្រុមជំនួយកិច្ចការ បាន អញ្ជើញជាគ្រូបង្គោលធ្វើបទឧទ្ទេសច្បាប់ ដល់សិក្ខាកាមជាកងអនុសេនាធំវិស្វកម្មសំណង់លេខ៤៣២ ដែលត្រៀម បំពេញបេសកកម្មរក្សាសន្តិភាពនៅសាធារណរដ្ឋលីបង់ ចំនួន **៦៣**នាក់ (ស្រី **២២**នាក់) នៅសាលាហ្វឹកហ្វឺនបណ្តុះបណ្តាល កងកម្លាំងរក្សាសន្តិភាពពហុជាតិ។
- **ខេត្តកំពង់ចាម៖**
  - ស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម បានចូលរួមជាវាគ្មិន៖ ក/ក្រោមប្រធានបទ ស្តីពី៖ ១-«ការ ផ្សព្វផ្សាយពីនិតិវិធីដល់ប្រជាពលរដ្ឋ ដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស» ០១លើក។ ២-ការពង្រឹងប្រសិទ្ធភាពផ្សព្វផ្សាយនីតិវិធីដល់ប្រជាពលរដ្ឋ ដែលត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយជន បរទេស ចំនួន ០១លើក។ ខ/នៅតាមវិទ្យុជាតិខេត្ត ០១លើក ស្តីពី ការទប់ស្កាត់ចំណាកស្រុកខុសច្បាប់ ក្រោយពីពិធីបុណ្យចូលឆ្នាំថ្មី។ គ/ក្នុងវិទ្យុ ក្រោមប្រធានបទ «**ការផ្សព្វផ្សាយពីនីតិវិធី ដល់ប្រជាពលរដ្ឋ ចំពោះការរៀបការជាមួយជនបរទេស**»។
  - មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចូលរួមជាវាគ្មិនក្នុងសិក្ខាសាលាក្រោមប្រធានបទ បិទបញ្ចប់គម្រោង ស្តីពី ៖ ១- ការលើកកម្ពស់ និងការការពារសិទ្ធិរបស់ពលករកម្ពុជា ដែលមានជំនាញ ទាបនៅប្រទេសថៃ" ដែលអនុវត្តដោយ អង្គការ LSCW និង We World ០១លើក។ ២-ការអប់រំ ផ្សព្វផ្សាយចំណេះដឹងដល់ប្រជាពលរដ្ឋ ពីផលប៉ះពាល់នៃអំពើជួញដូរមនុស្ស ពង្រឹងប្រសិទ្ធភាព ផ្សព្វផ្សាយ និងទប់ស្កាត់ការធ្វើចំណាកស្រុកដោយខុសច្បាប់ ការទប់ស្កាត់ភាពមិនប្រក្រតី ក្នុងថ្ងៃទិវា បុណ្យនៃក្តីស្រលាញ់ និងការបណ្តុះបណ្តាលជំនាញដាំដុះដល់ស្ត្រី ដើម្បីលើកស្ទួយជីវភាពគ្រួសារ បានចំនួន ០៤លើក។ ៣-ការការពារសិទ្ធិរបស់ពលករដែលមានជំនាញទាបនៅប្រទេសថៃ។ ៤-ក្នុងវិទ្យុ ក្រោមប្រធានបទ «**ការទប់ស្កាត់ការចំណាកស្រុកខុសច្បាប់ ក្រោយពិធីបុណ្យចូលឆ្នាំថ្មី**»។

- **រដ្ឋបាលក្រុងកំពង់ចាម** បានចូលរួមជាវាគ្មិន ចំនួន ០៣លើក ក្រោមប្រធានបទ៖១-ដំណោះស្រាយបញ្ហាប្រឈមរបស់ពលករចំណាកស្រុកក្នុងកំឡុងពេលកូវីដ-១៩។ ២-ការទប់ស្កាត់ពលរដ្ឋកុំឲ្យឆ្លងដែនខុសច្បាប់ទៅប្រទេសជិតខាង ក្នុងកំឡុងពេល កូវីដ-១៩។

- **ខេត្តបាត់ដំបង៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានរួមចូលជាវាគ្មិន៖
  - នៅក្នុងវេទិកាផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ឱកាសស្វែងរកការងាររបស់ប្រជាពលរដ្ឋ និងវិធានការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ នៅស្រុកកំរៀង និងស្រុកសំពៅលូន ០១លើក។
  - ផ្សព្វផ្សាយស្តីពី ការធ្វើចំណាកស្រុកដោយសុវត្ថិភាព រៀបចំដោយអង្គការប្រតិបត្តិការកុមារកម្ពុជា នៅស្រុកថ្មគោល ០១លើក មានអ្នកចូលរួម ៣០នាក់ ស្រី ១៦នាក់។

១.១.៥ ការផ្សព្វផ្សាយតាមរយៈឧបករណ៍(IEC)

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖** បានផ្សព្វផ្សាយ និងចែកខិត្តបណ្ណព័ត៌មានអំពីការធ្វើទេសន្តរប្រវេសន៍ការងារប្រកបដោយសុវត្ថិភាពដល់ពលករទេសន្តរប្រវេសន៍ និងប្រជាពលរដ្ឋដែលមានបំណងធ្វើទេសន្តរប្រវេសន៍ការងារ ដោយសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច តាមរយៈមណ្ឌលធនធានពលករ (MRC) ខេត្តសៀមរាប ខេត្តកំពង់ធំ ខេត្តបាត់ដំបង និងខេត្តកំពត។
- **ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ៖** នាយកដ្ឋានសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ បានបញ្ចូលសារអប់រំពាក់ព័ន្ធការ បង្ការ ទប់ស្កាត់អំពើជួញ ដូរមនុស្សទៅក្នុង CD,VCD,DVD របស់ផលិតកម្មភាពយន្ត និងក្រុមហ៊ុននាំចេញ-នាំចូលខ្សែភាពយន្ត បានចំនួន ៣៧៦.៣២៤ផលិតផល។
- **ខេត្តបន្ទាយមានជ័យ៖** លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តមន្ទីរអង្គភាពពាក់ព័ន្ធ អាជ្ញាធរ ក្រុង ស្រុក បានសហការជាមួយអង្គការដៃគូះធ្វើការផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈចែកប័ណ្ណ ដូចជា៖
  - អង្គការសាម៉ារីតាន់ភឺស ចែកប័ណ្ណការអប់រំផ្សព្វផ្សាយ សរុបចំនួន ២៤.៧៥៧នាក់ (ស្ត្រី ៧.៨៧០នាក់) អនីតិជន ១០.២៩៧នាក់(កុមារី ៨៦៩នាក់)។
  - អង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) បានចែកប័ណ្ណការអប់រំផ្សព្វផ្សាយ សរុបចំនួន ៩.៧១៦នាក់ (ស្រី ១.១៧៤នាក់)។
  - អង្គការដំណក់ទឹក បានចែកប័ណ្ណការអប់រំផ្សព្វផ្សាយ សរុបចំនួន ចំនួន ៧.០៥៤នាក់។
- **ខេត្តបាត់ដំបង៖** អង្គការសាម៉ារីតាន់ភឺស បានផ្តល់ការអប់រំ និងចែកខិត្តប័ណ្ណផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ពលករចំនួន ៦៩៣នាក់ (ស្ត្រី ៣៤៧នាក់) កុមារ ៥៤នាក់។
- អង្គការមូលនិធិអេ២១៖ បានធ្វើការចែកជូននូវសៀវភៅ ស្តីពីកិច្ចការពារខ្លួនពីការជួញដូរមនុស្ស និងប័ណ្ណផ្តល់ព័ត៌មាន ស្តីពីករណីជួញដូរមនុស្ស បានចំនួន ៤០០យីត។

## ២. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

### ២.១. ការបង្កើតកម្មវិធីសិក្សា ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
  - បានផ្តល់កម្មវិធីតម្រង់ទិសវិជ្ជាជីវៈនៅតាមសាលាមធ្យមសិក្សាចំណោះទូទៅ ១៨៣សាលា ដែលមានសិស្សសរុបចំនួន ៤១.៣៨៤នាក់ (ស្រី ១៩.០៧៨នាក់)
  - បានផ្តល់សេវាប្រឹក្សាយោបល់ អំពីអាជីពការងារ និងវិជ្ជាជីវៈដល់អ្នកមកទទួលសេវា ចំនួន ៤.៣១៩នាក់។
  - រៀបចំវគ្គណែនាំតម្រង់ទិសពលករមុនពេលចេញដំណើរទៅបរទេសចំនួន ២៥លើក ដែលមានពលករចំនួន ១.៦៥៧នាក់ (ស្រី ៦៨២នាក់)

- ○ បានចាប់ផ្តើមដាក់ឱ្យដំណើរការជាផ្លូវការប្រព័ន្ធជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈការងារពីចម្ងាយ ឬតាមអនឡាញ (National TVET E-learning Platform)។
- ○ បានពង្រឹង និងបង្កើនការផ្សព្វផ្សាយអំពីវិស័យអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈការងារ ដោយបាន៖ ១-ផ្សព្វផ្សាយតាមប្រព័ន្ធ Online ចំនួន ៤.១៣៩ដង។ ២-ចងក្រង និងផលិតស្ពតផ្សព្វផ្សាយ ចំនួន ៩៥ដង។ ៣- ចុះផ្សព្វផ្សាយតាមភូមិភាគចំនួន ៥ដង។ ៤-ធ្វើកម្មវិធី Roadshow និងផ្សព្វផ្សាយនៅតាមសហគមន៍បានចំនួន ៨៦ដង ដែលមានសិស្សចំនួន ៦.៣៧៨នាក់ (ស្រី ៣.៣៦២នាក់)។

**២.២. វិធានការបង្ការ ទប់ស្កាត់ ដោយការគ្រប់គ្រងចំណាកស្រុកខុសច្បាប់**

- **អគ្គស្នងការដ្ឋាននគរបាលជាតិ៖** កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្ត ចំនួន ០៣(នគរបាល និង យោធា) បានធ្វើការទប់ស្កាត់ ពលករចំណាកស្រុកខុសច្បាប់នៅតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ ចំនួន ៤៧លើក មនុស្ស ៧៨៣នាក់ (ស្រី ៣២៤នាក់) អនីតិជន ១០៩នាក់ បានធ្វើកិច្ចសន្យាការអប់រំណែនាំកុំឱ្យចំណាកស្រុកខុសច្បាប់ ទៅក្រៅប្រទេសទៀត និងបញ្ជូនទៅមណ្ឌលចត្តាឡីស័ក ក្នុងនោះមាន៖
  - ○ ខេត្តបាត់ដំបង ចំនួន ០៦លើក មនុស្សចំនួន ១០២នាក់(ស្រី៤៧នាក់) អនីតិជន ២៥នាក់ ។
  - ○ ខេត្តបន្ទាយមានជ័យ ចំនួន ៤០លើក មនុស្សចំនួន ៦៧២នាក់(ស្រី ២៧៣នាក់) អនីតិជន ៨៤នាក់
  - ○ ខេត្តឧត្តរមានជ័យ ចំនួន ០១លើក មនុស្សចំនួន ០៩នាក់ (ស្រី ០៤នាក់)។
- **ការិយាល័យទំនាក់ទំនងព្រំដែនកម្ពុជា-ថៃ នៃគណៈកម្មាធិការព្រំដែនទូទៅកម្ពុជា-ថៃ** បានធ្វើការសហការ និងសម្របសម្រួលជាមួយអាជ្ញាធរថៃ ដែលបានចាប់ពលរដ្ឋខ្មែរឆ្លងដែនខុសច្បាប់ចំនួន ៥៩នាក់ (ស្រី ៣១នាក់) ឱ្យបានមាតុភូមិនិវត្តន៍មកប្រទេសកម្ពុជាវិញ។
- ✓ ក្រោយពីបានទទួល និងឃាត់ខ្លួនពលរដ្ឋទាំងនោះ ក៏បានធ្វើកិច្ចសន្យាអប់រំ ណែនាំកុំឱ្យចំណាកស្រុកខុសច្បាប់ទៅក្រៅប្រទេសទៀត ហើយឱ្យវិលត្រឡប់ទៅលំនៅដ្ឋានវិញ និងបញ្ជូនមេខ្យល់ ០១នាក់ទៅតុលាការដើម្បីចាត់ការតាមនីតិវិធី។

**២.៣. ការធ្វើអធិការកិច្ច និងពង្រឹងប្រសិទ្ធភាពលើការអនុវត្តការងារ**

▪ **ថ្នាក់ជាតិ៖**

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បាន៖**
  - បានចុះអធិការកិច្ចការងារលើលក្ខខណ្ឌនៃការងារទូទៅចំនួន ៣១៩លើក ក្នុងនោះការចុះធ្វើអធិការកិច្ចការងារសាមញ្ញចំនួន ១២៤លើក និងអធិការកិច្ចការងារពិសេសចំនួន ៦៩លើក និងបានដាក់កំហិតរោងចក្រ សហគ្រាសចំនួន ១២៦ និងផាកពិន័យរោងចក្រ សហគ្រាសចំនួន ៤។
  - បានប្រមូល និងផ្សព្វផ្សាយព័ត៌មានជ្រើសរើសកម្លាំងពលកម្មចំនួន ៤១.៩៩០កន្លែង និងវគ្គអប់រំបណ្តុះបណ្តាល និងអាហារូបករណ៍ចំនួន ២៦៧វគ្គ ពីគ្រប់ប្រភព។
  - បានរៀបចំពិព័រណ៍ចល័តការងារចំនួន ៤២ដង ដែលមានអ្នកចូលរួមសរុបចំនួន ៩.៥២១នាក់
  - បានរៀបចំកម្មវិធីវេទិកាការងារចំនួន ២៤ដង ដែលមានអ្នកចូលរួមសរុបចំនួន ២.៦៥៩នាក់។
  - ប្រជាពលរដ្ឋ សិស្ស និស្សិតចូលប្រើប្រាស់គេហទំព័រការងារទីភ្នាក់ងារជាតិមុខរបរ និងការងារ មានចំនួន ១២៩.៦១៨លើក។
  - ចំនួនអ្នកទទួលបានព័ត៌មានអំពីទីផ្សារការងារ តាមរយៈទំព័រ Facebook មានសរុបចំនួន ២៤៩.៣៤៨នាក់។
  - ចំនួនអ្នកប្រើប្រាស់សេវាតាមរយៈកម្មវិធីស្វែងរកការងារលើទូរស័ព្ទវៃឆ្លាតមានសរុប ៧៩២នាក់។
- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ)៖**
  - ក្រុមការងារការិយាល័យនីតិកម្ម និងអធិការកិច្ច បានចុះអធិការកិច្ចមជ្ឈមណ្ឌលរបស់អង្គការដែលមានកិច្ចព្រមព្រៀង ជាមួយក្រសួង ស.អ.យ និងមណ្ឌលសំចត សរុបចំនួន ១៩មណ្ឌល (មជ្ឈមណ្ឌល

របស់អង្គការមាន ១៧មណ្ឌល និងមណ្ឌលសំចតប៉ោយប៉ែតរបស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះចំនួន០១កន្លែង) ដែលមានទីតាំងស្ថិតនៅរាជធានីភ្នំពេញ ខេត្តសៀមរាប បាត់ដំបង និងខេត្តបន្ទាយមានជ័យ ដើម្បីត្រួតពិនិត្យដល់មជ្ឈមណ្ឌលទាំងអស់នោះត្រូវតែអនុវត្តទៅតាមគោលការណ៍ណែនាំរបស់ក្រសួង។

- ក្រុមការងារការិយាល័យគ្រប់គ្រងករណី និងការិយាល័យសង្គ្រោះ បានសហការជាមួយបណ្តាញ(3PC) ធ្វើការចុះស្វែងរក និងប៉ាន់ប្រមាណគ្រួសាររងគ្រោះដោយអំពើជួញដូរមនុស្ស មុនមាតុភូមិនិវត្តន៍ ដើម្បីបញ្ជូនជនរងគ្រោះទៅទទួលសេវាបន្តនៅអង្គការដៃគូ និងទៅសហគមន៍វិញ បន្ទាប់ធ្វើចត្តាឡីស័ករួចដោយមានការគាំទ្រពីអង្គការយូនីសេហ្វ។

- **ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ៖** បានធ្វើការណែនាំដល់ចាហ្វាងផលិតកម្មភាពយន្តឯកជន ឱ្យដំឡើងសារអប់រំផ្សព្វផ្សាយ ស្តីពីផលប៉ះពាល់នៃអំពើជួញដូរផ្លូវភេទ ទេសន្តរប្រវេសន៍ខុសច្បាប់ អំពើពពោះជំនួស និងអំពើជួញដូរសរីរាង្គ ទៅក្នុងផលិតផលខ្សែភាពយន្ត ចម្រៀងកាយវិការ និងចម្រៀងខារ៉ាអូខេនៅរៀងរាល់ពេលដែលសុំទិដ្ឋាការ បានចំនួន ៧០ក្រុមហ៊ុន និងផលិតកម្ម។

- **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**
  - បានដាក់ចេញនូវវិធានការគ្រប់គ្រងស្ថានភាព ការទទួល ការបញ្ជូនពលករតាមបណ្តាច្រកព្រំដែន និងការធ្វើសមាហរណកម្មតាមបណ្តាមូលដ្ឋានថ្នាក់ក្រោមជាតិ ដោយរក្សាសុវត្ថិភាពសុខភាព តាំងពីដំណាក់កាលដំបូង នៃការប្រកាសបិទព្រំដែនរបស់ថៃ។
  - បានសហការជាមួយអង្គការការីតាស់ស្វីស បង្កើតមណ្ឌលទទួលពលករកំរៀង ក្នុងខេត្តបាត់ដំបង ដើម្បីដោះស្រាយបញ្ហាពលករដែលឆ្លងកាត់ព្រំដែន។

- **អង្គការដៃគូ៖**
  - **អង្គការអេ២១ អង្គការក្តីស្រឡាញ់គ្មានព្រំដែន អង្គការគ្រួសារថ្មី និងអង្គការយូនីសេហ្វ** បានសហការជាមួយប្រធានក្រុមការងារ និងមន្ត្រីមជ្ឈមណ្ឌលសំចតប៉ោយប៉ែត បានចុះពិនិត្យ និងសួរសុខទុក្ខករណីកុមាររងគ្រោះនិងងាយរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន ០៣នាក់ និងគ្រួសាររបស់កុមាររងគ្រោះចំនួន ០២គ្រួសានៅក្នុងសហគមន៍ ដែលមានទីតាំងនៅក្នុងសៀមរាប ខេត្តសៀមរាប និង(ស្រុកមង្គលបុរី/ ក្រុងប៉ោយប៉ែត) ខេត្តបន្ទាយមានជ័យ។

▪ **ថ្នាក់ក្រោមជាតិ៖**

- **លេខាធិការដ្ឋានរាជធានី ខេត្ត** បានធ្វើសេចក្តីរាយការណ៍ជាប្រចាំអំពីពលករ និងពលរដ្ឋ ដែលវិលត្រឡប់ពីបរទេស ដើម្បីតាមដានស្ថានភាពសុខភាព ជីវភាព និងធ្វើការអប់រំបង្ការទប់ស្កាត់ ការវិលត្រឡប់ទៅប្រទេសគោលដៅដោយប្រថុយប្រថាន តាមការញុះញង់ពីមេខ្យល់ និងសហការជាមួយអង្គការដៃគូ ដើម្បីធ្វើការប៉ាន់ប្រមាណអំពីភាពប្រឈម និងសេចក្តីត្រូវការ ក្នុងពេលធ្វើសមាហរណកម្ម និងបានសហការជាមួយអង្គការដៃគូ សប្បុរសជន ផ្តល់ការឧបត្ថម្ភគាំទ្រផ្នែកសុខភាព និងជីវភាព។

## ២.៤. ការគ្រប់គ្រងស្ថិតិ៖ បច្ចុប្បន្នភាពចំណាកស្រុក និងចំណូលស្រុក

នៅក្នុងឆមាសទី១ ឆ្នាំ២០២២នេះ តាមរបាយការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ពលករខ្មែរដែលបានបញ្ជូនទៅធ្វើការនៅបរទេសតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន និងតាមរយៈប្រព័ន្ធអនុគ្រោះមុខរបរ Employment Permit System (EPS) របស់រាជរដ្ឋាភិបាល មានចំនួនសរុប ៩.១១២នាក់ (ស្រី ៣.៨០៩នាក់) ក្នុងនោះមាន៖

| | | |
|---|---|---|
| - សាធារណរដ្ឋកូរ៉េ | ចំនួន ១.៦៤៩នាក់ | (ស្រី ៥៣៥នាក់) |
| - ប្រទេសជប៉ុន | ចំនួន ២.៩៧៥នាក់ | (ស្រី ១.៣០១នាក់) |
| - ប្រទេសថៃ | ចំនួន ៤.៤៥៥នាក់ | (ស្រី ១.៩៤០នាក់) |
| - ប្រទេសសិង្ហបុរី | ចំនួន ២៤នាក់ | (ស្រី ២៤នាក់) |
| - តំបន់រដ្ឋបាលពិសេសហុងកុង | ចំនួន ០៩នាក់ | (ស្រី ០៩នាក់)។ |

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បាន៖

១-ដាក់ឱ្យដំណើរការប្រព័ន្ធគ្រប់គ្រងពលករទៅធ្វើការនៅក្រៅប្រទេស សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជន និងប្រព័ន្ធតាមដាន ជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករ រហូតដល់ពលករវិលត្រឡប់មកមាតុប្រទេសវិញ។

២-បានរៀបចំ និងពង្រឹងប្រព័ន្ធ OCWC (Oversea Cambodian Working Card) ពាក់ព័ន្ធនឹងពលករទេសន្តរប្រវេសន៍ ដូចជាការបែងចែកទៅតាមភេទ អាយុ កម្រិតអប់រំ និងប្រភេទការងាររបស់ពលករជាដើម សម្រាប់ធ្វើជាធាតុចូល ក្នុងការរៀបចំគោលនយោបាយ ឬបទដ្ឋានគតិយុត្ត។

៣-បានពង្រឹងប្រព័ន្ធស្វ័យប្រវត្តិកម្ម ដើម្បីតាមដានលំហូរនីតិវិធីនៃការធ្វើទេសន្តរប្រវេសន៍ការងារនៅគ្រប់ប្រទេសទទួល។

- **អគ្គស្នងការដ្ឋាននគរបាលជាតិ**

- ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ទាំង២៥ បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរធ្វើចំណាកស្រុកទៅក្រៅប្រទេស ទាំងស្របច្បាប់ មិនស្របច្បាប់ និងដាច់ការទាក់ទង សរុបចំនួន **១០៦.៦០១**នាក់(ស្រី **៤៦.៥១៧**នាក់) អនីតិជន **៩៤២**នាក់(ស្រី **៣២៣**នាក់)។ រួមមាន៖
  - ចេញដោយស្របចំនួន **៧២.១៧៧**នាក់(ស្រី **៣៦.៥៣៥**នាក់) អនីតិជន **១៧០**នាក់(ស្រី **៦៤**នាក់។
  - ចេញដោយមិនស្របច្បាប់ចំនួន **៣២.៨៦១**នាក់(ស្រី **៩.៧១៦**នាក់) អនីតិជន **៦៦៨**នាក់(ស្រី **២៣០**នាក់)។
  - ដាច់ការទាក់ទងចំនួន **៥៦៣**នាក់(**ស្រី ២៦៦**នាក់) អនីតិជន **១០៤**នាក់(ស្រី **២៩**នាក់)។
- ទិន្នន័យពលរដ្ឋខ្មែរធ្វើចំណាកស្រុកត្រឡប់ពីក្រៅប្រទេសដោយខ្លួនឯង ទាំងស្របច្បាប់ និងមិនស្របច្បាប់ពីស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត សរុបចំនួន **១៥៦.៣៥០**នាក់(ស្រី **៧១.៣០២**នាក់) អនីតិជន **៨០៩**នាក់(ស្រី **៣០៧**នាក់)។
- **រដ្ឋបាលរាជធានី ខេត្ត ចំនួន ១៦** ចាប់ពីខែមករា ដល់ខែមិថុនា ឆ្នាំ២០២២ បានប្រមូលទិន្នន័យជាប្រចាំនូវចំនួនពលករវិលត្រឡប់ជារៀងរាល់ថ្ងៃ សរុបប្រមាណ **៩៤.១៣៦**នាក់ មានស្ត្រីប្រមាណ **៣៩.២៨១**នាក់ **(៤១,៧២%)** ដែលភាគច្រើន មិនមានសេសសល់ប្រាក់ចំណូលសម្រាប់ការផ្គត់ផ្គង់ខ្លួន ឬគ្រួសារនៅឯស្រុកទេ។

*តារាងពលករវិលត្រឡប់គិតពីខែមករា ដល់ខែមិថុនា ឆ្នាំ២០២២*

| ល.រ | ខេត្ត | ចំនួនអ្នកវិលត្រឡប់សរុប | ស្ត្រី | ផ្សេងៗ |
|---|---|---|---|---|
| ១ | ព្រៃវែង | ២១៣ | ៨៦ | |
| ២ | ស្វាយរៀង | ១១ | ០៨ | |
| ៣ | កំពត | ៦០៣ | ៣៤២ | |
| ៤ | តាកែវ | ៥១២ | ២០៥ | |
| ៥ | កែប | ០៣ | ០២ | |
| ៦ | កោះកុង | ១.៤២២ | ៤៨៥ | |
| ៧ | ក្រចេះ | ២.៣៥១ | ៧១២ | |
| ៨ | ត្បូងឃ្មុំ | ៨.៤៤៩ | ៣.៤០៦ | |
| ៩ | ឧត្តរមានជ័យ | ១.០៧៨ | ៥៣៦ | |
| ១០ | បន្ទាយមានជ័យ | ៣១.៦៨៥ | ១៣.៤៥៨ | |
| ១១ | ប៉ៃលិន | ១៣.១៣១ | ៥.០១២ | |
| ១២ | បាត់ដំបង | ១.១៦៤ | ៥២៨ | |
| ១៣ | ពោធិសាត់ | ២២០ | ១០៩ | |

| | | | | |
|---|---|---|---|---|
| ១៤ | កំពង់ឆ្នាំង | ២១ | ០៧ | |
| ១៥ | ព្រះវិហារ | ០៨ | ០៦ | |
| ១៦ | សៀមរាប | ៣៣.២៦៥ | ១៤.៣៧៩ | |
| សរុប | | ៩៤.១៣៦ នាក់ | ៣៩.២៨១ នាក់ | |

## ២.៥. វិធានការគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ

- **អគ្គស្នងការដ្ឋាននគរបាលជាតិ**
  - ស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ កំពត ព្រៃវែង ក្រចេះ និងខេត្តរតនគិរី ល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ បានចំនួន **៤៨**លើក។
  - ស្នងការដ្ឋាននគរបាលខេត្តតាកែវ កែប ក្រចេះ ព្រៃវែង កោះកុង និងខេត្តព្រះសីហនុ បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ចារកម្ម ដល់ម្ចាស់ជាជីវកម្មផ្ទះសំណាក់ ហាងម៉ាស្សា ជាប្រចាំក្នុងនោះមានរាយតារាងដូចខាងក្រោម៖

***តារាងបច្ចុប្បន្នភាពគោលដៅសេវាកំសាន្ត ដែលបានធ្វើការអប់រំដើម្បីបង្ការទប់ស្កាត់***
***អំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ឆ្នាំ២០២២***

| បរិយាយ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា |
|---|---|---|---|---|---|---|
| ចំនួនគោលដៅ | ១៥១ | ១៥៩ | ១៧៧ | ២៣៩ | ១៩៤ | ១៨៥ |
| ចំនួនមនុស្ស | ២០៤ | ២៨៥ | ៣០១ | ៦៧៦ | ៥១៧ | ៤៩៨ |
| ចំនួនស្ត្រី | ១៤១ | ២០៩ | ២២៥ | ៥៣២ | ៣៩០ | ៣៣៤ |

## ២.៦. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

- **ក្រសួងមហាផ្ទៃ**

  នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (**ក្រុមការងារអនុវត្តន៍ច្បាប់**) បានធ្វើសម្ភាសន៍ពលរដ្ឋខ្មែរ និងជនបរទេសដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ចំនួន **៥៩៩**នាក់(ស្រី **៩៨**នាក់) ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ និងបានប្រមូលព័ត៌មានពីការសួរសុខទុក្ខនារីខ្មែរ ដែលរៀបការទៅរស់នៅប្រទេសកូរ៉េខាងត្បូងចំនួន **៥៩**នាក់(ស្រី **៣៧**នាក់)។

# ៣. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បាន៖
  - ចូលរួមជាគណៈអធិបតីក្នុងកម្មវិធីចែកសម្ភារសិក្សា និងកង់ដល់កុមារ ក្នុងគម្រោងកិច្ចអន្តរាគមន៍ស្នូលក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ និងសិប្បកម្មជំឡុងមី និងមានការផ្សព្វផ្សាយការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ ដើម្បីឱ្យកុមារបានចូលសិក្សា ក្នុងខេត្តគោលដៅចំនួន៥ រួមមានខេត្តសៀមរាប ត្បូងឃ្មុំ ពោធិ៍សាត់ បាត់ដំបង និងខេត្តកំពង់ចាម ដែលមានអ្នកចូលរួមសរុបចំនួន **១.១០២**នាក់ (ស្រី **៤៥៣**នាក់)។
  - បានផ្តល់ទិដ្ឋាការប្រើប្រាស់កម្មករនិយោជិតវ័យក្មេងចំនួន ៤សហគ្រាស។
  - បានផលិតវីឌីអូស្ពត ស្តីពីការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ។
  - បានរៀបចំកិច្ចប្រជុំបន្ត ដើម្បីពិនិត្យ និងកែសម្រួលកម្រងសំណួរក្នុងការចុះអធិការកិច្ចលើសិប្បកម្មផលិតឥដ្ឋ និងចម្ការជំឡុងមី ដើម្បីជៀសវាងការងារដោយបង្ខំ និងពលកម្មកុមារ។
- **ខេត្តក្រចេះ៖**
  - មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានចុះធ្វើអធិការកិច្ចលើការថែទាំជំនួសចំពោះកុមារ នៅមណ្ឌលអង្គការដំណឹងល្អទាំងបួន និងភូមិកុមារកម្ពុជា SOS ខេត្តក្រចេះ **០៣**លើក ជាលទ្ធផលឃើញថា ការថែទាំ និងការការពារឧបត្ថម្ភដល់កុមារ បានដំណើរការល្អប្រសើរ។

- មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានចុះទៅណែនាំផ្សព្វផ្សាយករណីពលកម្មកុមារ នៅតាមបណ្តារោងចក្រសិប្បកម្ម ទឹកពិសារដប ដញ្ជីងថ្លឹងទំងន់(ដញ្ជីងតោន)ស្ថានីយ៍ប្រេងឥន្ធនៈបានចំនួន **២៧**មូលដ្ឋាន មានបុគ្គលិកចំនួន ៨០នាក់ (ស្រី **២៩**នាក់) មានខ្លឹមសារដូចជា ដើម្បីទប់ស្កាត់ជួញដូរកម្លាំងពលកម្មកុមារ និងទប់ស្កាត់រាល់សកម្មភាពជួញដូរ និងប្រើអំពើហិង្សាលើបុគ្គលិកកម្មករ (ពិសេសកុមារ)។

- **ខេត្តកំពង់ចាមៈ** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចុះទៅណែនាំផ្សព្វផ្សាយករណីពលកម្មកុមារនៅតាមឡឥដ្ឋ រោងចក្រសហគ្រាស កន្លែងលាងឡាន និងកន្លែងកំសាន្ត និងបានផ្សព្វផ្សាយដល់សហគមន៍ ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស តាមរយៈការចុះពិនិត្យតាមដាន ការប្រជុំក្រុមឳពុកម្តាយកុមារតូចអាយុ ០ឆ្នាំ ដល់៣ឆ្នាំ តាមស្រុក ឃុំ ភូមិគោលដៅមួយចំនួន។
- **ខេត្តបន្ទាយមានជ័យៈ** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានៈ
  - សហការជាមួយអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ បានធ្វើការចុះផ្សព្វផ្សាយការលុបបំបាត់ពលកម្មកុមារក្នុងវិស័យផលិតឥដ្ឋ នៅឃុំទឹកជោរស្រុកព្រះនេត្រព្រះខេត្តបន្ទាយមានជ័យ ចំនួន ០៥លើក។
  - បញ្ជ្រាបដល់ មាតាបិតា អាណាព្យាបាល សិស្សានុសិស្ស ក្នុងការទប់ស្កាត់ធ្វើចំណាកស្រុក ការប្រើអំពើហិង្សាលើកុមារ និងការកេងប្រវ័ញ្ចកម្លាំងពលកម្មលើកុមារ ក្នុងពិធីសម្ពោធអគារសាលប្រជុំថ្មី នៅក្នុងបរិវេណអនុវិទ្យាល័យ កូនត្រី ស្រុកអូរជ្រៅ ដែលមានសមាសភាពចំនួន ២០០នាក់(ស្រី **៥៩**នាក់)។
- **ខេត្តប៉ៃលិនៈ** បានចុះអធិការកិច្ចដើម្បីទប់ស្កាត់ និងលុបបំបាត់នូវទម្រង់ជួញដូរដ៏ធ្ងន់ធ្ងរលើពលកម្មកុមារនៅតាមសហគ្រាស គ្រឹះស្ថានដែលមានការប្រើប្រាស់កម្លាំងពលកម្មដូចជា សៃឡូ កាស៊ីណូ ឡឥដ្ឋ ភោជនីយដ្ឋាន និងអាហារដ្ឋាន ចំនួន ៨០កន្លែង ជាលទ្ធផលរកពុំឃើញមានជួញដូរកម្លាំង ពលកម្មកុមារទេ។
- **ខេត្តសៀមរាបៈ**
  - មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានៈ ១-ចុះតាមដានការប្រើប្រាស់ពលកម្មកុមារក្នុងវិស័យកសិកម្ម (ដំឡូងមី) ព្រមទាំងបានធ្វើការផ្សព្វផ្សាយអំពីប្រកាសពាក់ព័ន្ធនឹងពលកម្មកុមារក្នុងវិស័យកសិកម្ម ដល់អាណាព្យាបាល និងកុមារ នៅស្រុកអង្គរជុំ បានចំនួន ០១លើក ដែលមានអ្នកចូលរួមសរុប ៥០នាក់ (ស្រី ២២នាក់)។ ២-សហការជាមួយស្នងការដ្ឋាននគរបាលខេត្ត និងកងរាជអាវុធហត្ថខេត្ត បានធ្វើការប្រជុំពិភាក្សាលើការកំណត់នីតិវិធីក្នុងការទប់ស្កាត់ និងដកហូតកុមារក្នុងទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ នៅតាមសហគ្រាសអាជីវកម្មផលិតឥដ្ឋ ចំនួន ០១លើក ដែលមានអ្នកចូលរួមសរុប ០៨នាក់ (ស្រី ០៤នាក់)។ ៣-ចុះតាមដាន ស្រង់ស្ថិតិកម្មករ និងកុមារដែលស្នាក់ជាមួយឳពុកម្តាយនៅក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ ព្រមទាំងបានធ្វើការផ្សព្វផ្សាយបន្ថែមអំពីកម្រងប្រកាសទាំង១៣ ពាក់ព័ន្ធនឹងទម្រង់ពលកម្ម និងសេចក្តីណែនាំលេខ០៥៦/១៩ ក.ប/ស.ណ.ន.ខ.ល ស្តីពីការហាមក្មេងចូលទៅក្នុងបរិវេណខ្សែចង្វាក់ផលិតកម្មផលិតឥដ្ឋ ដល់ម្ចាស់អាជីវកម្ម អាណាព្យាបាល និងកុមារ នៅឃុំដានរុន ស្រុកសូទ្រនិគម និងស្រុកជីក្រែង ដើម្បីបង្ការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារចំនួន ០២លើក អ្នកចូលរួមសរុប ៥០នាក់ (ស្រី ២៦នាក់)។

**៤-ចុះ**ផ្តល់ជាសម្ភារសិក្សា សម្លៀកបំពាក់ និងកង់ម្នាក់០១គ្រឿង បានធ្វើផ្សព្វផ្សាយការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារដែលចូលរួមសកម្មភាពសេដ្ឋកិច្ច ក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ និងកសិឧស្សាហ៍កម្ម បានចំនួន ៩០នាក់ (ស្រី ៥៣នាក់)ដោយបានផ្តល់ជាសម្ភារសិក្សា សម្លៀកបំពាក់ និងកង់ម្នាក់ ០១គ្រឿង។

- **ខេត្តព្រះសីហនុ៖** ផ្នែកការពារសុវត្ថិភាពកុមារ អង្គការម្លប់តាប៉ាង បានដាក់បណ្តាញម៉ូតូឌុប និងក្រុមម៉ូតូកង់បី ផ្ទះសំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្រ បណ្តាញតាមសហគមន៍ ផ្នែកភ្នាក់ងារទេសចរណ៍សរុបចំនួន **១.១៣៣**នាក់។
- **ខេត្តរតនគិរី៖** មន្ទីរអប់រំ យុវជន និងកីឡា បានចុះពង្រឹងការងារក្រុមប្រឹក្សាកុមារកម្ពុជា និងបានធ្វើការផ្សព្វផ្សាយអំពីច្បាប់ពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញមនុស្ស ការរំលោភបំពាននានាលើកុមារ ការប្រើប្រាស់គ្រឿងញៀន ជូនដល់លោកនាយក នាយិកា លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ប្រធានប្រតិបត្តិ ប្រធានសាខា ក្នុងបរិបទកូវីដ-១៩ នៅសាលាបឋមសិក្សាកាឡែង ស្រុកលំផាត់ និងក្រុងបានលុង មានអ្នកចូលរួមសរុប **៥៥**នាក់។
- **ខេត្តមណ្ឌលគិរី៖** បានចុះអធិការកិច្ច ត្រួតពិនិត្យ និងស្រង់ស្ថិតិនៅតាមរីស៊តនានាចំនួន ១៩រីស៊តនៅជុំវិញខេត្ត ដើម្បីផ្សព្វផ្សាយច្បាប់ការងារ ស្តីពីការទប់ស្កាត់ និងលុបបំបាត់នូវទម្រង់ជួញដូរដ៏ធ្ងន់ធ្ងរលើពលកម្មកុមារ ដែលមានកម្មករ និយោជកចូលរួមចំនួន **១៤១**នាក់(ស្រី **៥១**នាក់)។
- **ខេត្តពោធិ៍សាត់** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានសហការជាមួយប្រតិភូក្រសួងការងារ និងបណ្តុះ បណ្តាលវិជ្ជាជីវៈបានចុះអធិការកិច្ច ត្រួតពិនិត្យដើម្បីផ្សព្វផ្សាយច្បាប់ ស្តីពីការទប់ស្កាត់ពលកម្មកុមារក្នុងវិស័យឡឥដ្ឋ នៅស្រុកបាកាន និងវិស័យ កសិកម្មនៅស្រុកវាលវែង។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### ១. ការងារអនុវត្តច្បាប់

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះទទួលបានពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត។

#### ១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន **៧៤**ករណី(ធៀបនឹងឆមាសទី១ ឆ្នាំ២០២១ មានចំនួន **១៩៨**ករណី ថយចុះចំនួន **១២៤**ករណី) ស្មើនឹង **៦២,៦២%** ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន **៨៣**នាក់ (ស្រី **០៨**នាក់) អនីតិជន **០៧**នាក់។ ក្នុងនោះជនសង្ស័យដែលជាជនបរទេសចំនួន **១២**នាក់ មាន **០៤**សញ្ជាតិ គឺជនជាតិចិន **០៩**នាក់ ជនជាតិថៃ **០១**នាក់ វៀតណាម **០១**នាក់ និងជនជាតិបង់ក្លាដេស **០១**នាក់។

សង្គ្រោះជនរងគ្រោះ ចំនួន **១៥៦**នាក់ (ស្រី **១០៥**នាក់) ក្នុងនោះ អាយុក្រោម១៥ឆ្នាំ **៦០**នាក់ អាយុ ១៥-១៧ឆ្នាំ **១៣**នាក់ និងអាយុពី១៨ឆ្នាំឡើង **៨៣**នាក់ (ប្រគល់ឱ្យមន្ទីរសង្គមកិច្ច **០៦**នាក់(ស្រី) និងប្រគល់ឱ្យគ្រួសារ **១៥០**នាក់(ស្រី **៩៩**នាក់) ក្នុងនោះចែកជា៖

**១. ករណីអំពើជួញដូរមនុស្ស**

បង្ក្រាបបាន **១៦**ករណី/ **១៣៩**ករណី (ថយចុះ **១២៣**ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន **២២**នាក់ (ស្រី **០២**នាក់) អនីតិជន **០១**នាក់ និងជនបរទេស **០៧**នាក់ មាន **០២**សញ្ជាតិ មានជនជាតិចិន **០៦**នាក់ និងជនជាតិថៃ **០១**នាក់។ សង្គ្រោះជនរងគ្រោះចំនួន **៧០**នាក់(ស្រី **៣០**នាក់) ក្នុងនោះ អាយុក្រោម១៥ឆ្នាំ **០៧**នាក់ អាយុ ១៥-១៧ឆ្នាំ **០៤**នាក់ និងអាយុ១៨ឆ្នាំឡើង **៥៩**នាក់ (ប្រគល់ឱ្យគ្រួសារ **៧០**នាក់(ស្រី **៣០**នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | មាត្រា | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|---|
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ១១ | ០៩ | ៤៤ | ១១ | ថៃ០១ |
| - អំពើលក់ដូរមនុស្ស | ១៤ | ០២ | ០៥ | ០៦ | ចិន០៦ |
| -អំពើលក់ដូរមនុស្សសម្រាប់នាំឆ្លងដែន | ១៦ | ០១ | ០ | ០១ | |
| -ការដឹកជញ្ជូនដោយមានគោលដៅ | ១៧ | ០១ | ១២ | ០១ | |
| -ការទទួលយកមនុស្សមានគោលដៅជួយដល់ជនល្មើស | ២០ | ០២ | ០៨ | ០២ | |
| -ការទិញពេស្យាចារកុមារ | ៣៤ | ០១ | ០១ | ០១ (អនី.០១) | |
| *សរុប* | | *១៦ករណី* | *៧០នាក់* | *២២នាក់* | *០៧នាក់* |

## ២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន ៥៨ករណី/៥៩ករណី(ថយចុះ ០១ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ៦១នាក់(ស្រី ០៦នាក់) អនីតិជន ០៦នាក់ និងជនបរទេស ០៥នាក់ មាន ០២សញ្ជាតិៈ ជនជាតិបង់ក្លាដេស ០១នាក់ ចិន ០៣នាក់ និងវៀតណាម ០១នាក់ សង្គ្រោះជនរងគ្រោះចំនួន ៨៦នាក់(ស្រី ៧៥នាក់) មានៈ អាយុក្រោម១៥ឆ្នាំ ៥៣នាក់ អាយុ១៥-១៧ឆ្នាំ ០៩នាក់ និងអាយុ១៨ឆ្នាំឡើង ២៤នាក់ (ប្រគល់ឱ្យមន្ទីរសង្គមកិច្ច ០៦នាក់(ស្រី) និងប្រគល់ឱ្យគ្រួសារ ៨០នាក់(ស្រី ៦៩នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | មាត្រា | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|---|
| -ស្ថានទម្ងន់ទោសនៃសញ្ជារកម្ម | ២៧ | ០២ | ២៣ | ០៣ | ចិន០២ |
| -សញ្ជារកម្មទាក់ទងនឹងពេស្យាចារកុមា | ២៨ | ០៣ | ០៨ | ០៣ | |
| -រូបភាព និងសម្ភារៈអាសអាភាស | ៣៩ | ០៣ | ០៣ | ០៣ | ចិន០១ |
| -រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ | ៤១ | ០២ | ០១ | ០២ | |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ៤២ | ៣៤ | ៣៧ | ៣៦ (អនី.០៦) | បង់ក្លាដេស០១ |
| -អំពើអាសប្រចាំងនឹងអនិតិជនអាយុក្រោម១៥ឆ្នាំ | ៤៣ | ១៤ | ១៤ | ១៤ | វៀតណាម០១ |
| *សរុប* | | *៥៨ករណី* | *៨៦នាក់* | *៦១នាក់* | *០៥នាក់* |

## ២. កិច្ចការយុត្តិធម៌

### ២.១. លទ្ធផលចំណាត់ការផ្តន្ទាទោស

ទិន្នន័យទទួលបានពីក្រុមការងារជំនាញកិច្ចការយុត្តិធម៌ ដែលបានដកស្រង់លទ្ធផលពីសាលាដំបូងរាជធានី-ខេត្ត បានធ្វើចំណាត់ការលើសំណុំរឿងបទល្មើសក្រោមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ ជាលទ្ធផលតាមដំណាក់កាលទាំង៣ នៃនីតិវិធីតុលាការ មានដូចខាងក្រោមៈ

១. <u>ចំណាត់ការរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត</u> ៖

សរុប ១៩៥សំណុំរឿង (ក្នុងនោះសំណុំរឿងចាស់ ៦០)

-**ជនរងគ្រោះ**ចំនួន **១១០**នាក់(ស្រី **៩៦**នាក់) ក្នុងនោះមានអនីតិជន **៧០**នាក់ (ស្រី **៦២**នាក់)។

-**ជនត្រូវចោទ**ចំនួន **១១១**នាក់(ស្រី **១៣**នាក់) ក្នុងនោះមានអនីតិជន **០២**នាក់។

➢ **បានធ្វើចំណាត់ការដោយៈ** បញ្ជូនទៅស៊ើបសួរចំនួន **១៤៦**សំណុំរឿង បញ្ជូនរឿងទៅជម្រះគ្មាន នីតិវិធីបង្ហាញខ្លួនភ្លាមគ្មាន តម្កល់ទុកឥតចាត់ការ **០៦**សំណុំរឿង បញ្ចូលសំណុំរឿងគ្មាន ផ្ទេរសមត្ថកិច្ច **០១**សំណុំរឿង សរុបស្មើចំនួន **១៥៣**សំណុំរឿង និងកំពុងចាត់ការចំនួន **៤២**សំណុំរឿង។ ដូចមានតារាងលម្អិតខាងក្រោមៈ

| ចំនួនសំណុំរឿង | ចំនួនជនរងគ្រោះ | | | | ចំនួនជនល្មើស | | | | ប្រភេទចំណាត់ការ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | បញ្ជូនទៅស៊ើបសួរ | បញ្ជូនរឿងទៅជម្រះ | នីតិវិធីបង្ហាញខ្លួនភ្លាម | តម្កល់ទុកឥតចាត់ការ | ផ្ទេរសមត្ថកិច្ច | កំពុងចាត់ការ |
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | | | | | |
| ១៩៥ | ០៦ | ៣៤ | ០៨ | ៦២ | ៩៦ | ១៣ | ០២ | ០ | ១៤៦ | ០០ | ០០ | ០៦ | ០១ | ៤២ |
| សរុប | ៤០នាក់ | | ៧០នាក់ | | ១០៩នាក់ | | ០២នាក់ | | | | | | | |
| សរុបរួម | ១១០ នាក់ | | | | ១១១នាក់ | | | | ១៥៣សំណុំរឿង | | | | | ៤២សំណុំរឿង |

២. <u>ចំណាត់ការរបស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានី-ខេត្ត</u> ៖

សរុបមានចំនួន **១៧៨**សំណុំរឿង (ក្នុងនោះសំណុំរឿងចាស់មា ៩៤ )

**-ជនរងគ្រោះ**ចំនួន **១៨៦**នាក់( ស្រី **១៣៧**នាក់) ក្នុងនោះមានអនីតិជន ៨៣នាក់ ( ស្រី **៧៤**នាក់) និងជនបរទេស **២៣**នាក់( ស្រី ០៤នាក់)

**-ជនត្រូវចោទ**ចំនួន **២៥០**នាក់ ( ស្រី ៤០នាក់) ក្នុងនោះមាននីតិជន **០៧**នាក់ ( ស្រី **០១**នាក់) និងជនបរទេស **១៤**នាក់(ប្រុស)។

➢ **បានធ្វើចំណាត់ការដោយៈ** បញ្ជូនរឿងទៅជម្រះចំនួន ៩២សំណុំរឿង លើកលែងចោទគ្មាន ផ្ទេរសម្ថកិច្ចគ្មាន សរុបសំណុំរឿងចាត់ការរួចស្មើនឹង ៩២សំណុំរឿង បណ្តឹងឧទ្ធរណ៍ ០១សំណុំរឿង និងកំពុងចាត់ការចំនួន ៨៦ សំណុំរឿង។ ដូចមានតារាងលម្អិតខាងក្រោមៈ

| ចំនួនសំណុំរឿង | ចំនួនជនរងគ្រោះ | | | | | | ចំនួនជនត្រូវចោទ | | | | | | ប្រភេទចំណាត់ការរួច | | | បណ្តឹងឧទ្ធរណ៍ | កំពុងចាត់ការ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | ជនបរទេស | | នីតិជន | | អនីតិជន | | ជនបរទេស | | បញ្ជូនរឿងទៅជម្រះ | លើកលែងបទចោទ | ផ្ទេរសមត្ថកិច្ច | | |
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | | | | |
| ១៧៨ | ២១ | ៥៩ | ០៩ | ៧៤ | ១៩ | ០៤ | ១៩០ | ៣៩ | ០៦ | ០១ | ១៤ | ០០ | ៩២ | ០០ | ០០ | ០១ | ៨៦ |
| សរុប | ៨០ នាក់ | | ៨៣ នាក់ | | ២៣ នាក់ | | ២២៩ នាក់ | | ០៧ នាក់ | | ១៤ នាក់ | | | | | | |
| សរុបរួម | ១៨៦ នាក់ | | | | | | ២៥០ នាក់ | | | | | | ៩២សំណុំរឿង | | | ០១ សំណុំរឿង | ៨៦ សំណុំរឿង |

៣. <u>ដំណាក់កាលចៅក្រមជំនុំជម្រះ នៃសាលាដំបូងរាជធានី-ខេត្តៈ</u>

សរុបមានចំនួន **២៨០**សំណុំរឿង (ក្នុងនោះសំណុំរឿងចាស់ ១៨១)

**-ជនរងគ្រោះ**ចំនួន ៣២៣នាក់( ស្រី ២០៦នាក់) ក្នុងនោះមានអនីតិជន **១៥៧**នាក់( ស្រី ៩៨នាក់) និងជនបរទេស ០៧នាក់( ស្រី ០២នាក់)។

**-ជនត្រូវចោទ**ចំនួន ៣៤៨នាក់( ស្រី ៤០នាក់) ក្នុងនោះមានអនីតិជន **១០**នាក់(ប្រុស) និងជនបរទេស ០៣នាក់( ស្រី ០១នាក់) អញ្ញាតជន ០២នាក់។

➢ **បានធ្វើចំណាត់ការរួចៈ** បញ្ជូនរឿងទៅជម្រះចំនួន **១២៤**សំណុំរឿង ផ្ទេរសមត្ថកិច្ច **០១**សំណុំរឿង **ប្រកាសសាលក្រមឱ្យៈ** រួចផុតពីបទចោទ **១២**សំណុំរឿង មានមនុស្សចំនួន ០៨នាក់(ស្រី ០៥នាក់), **ផ្តន្ទាទោសដោយៈ** ពិន័យជាប្រាក់ ០៤សំណុំរឿ ដាក់ពន្ធនាគារ **៧២**សំណុំរឿង មានមនុស្សចំនួន **៥៧**នាក់(ស្រី ១០នាក់), **ព្យួរទោសៈ** ព្យួរទោសសាកល្បង **០១**សំណុំរឿង ព្យួរទោសធម្មតា **០៦**សំណុំរឿងមានមនុស្សចំនួន **០២**នាក់(ស្រី), **បណ្តឹងឧបាស្រ័យៈ** បណ្តឹងជំទាស់ គ្មាន បណ្តឹងឧទ្ធរ **០២**សំណុំរឿង សរុបរឿងចាត់ការរួច **១២៥**សំណុំរឿង និងកំពុងចាត់ការ **១៥៥**សំណុំរឿង។ ដូចមានតារាងលម្អិតខាងក្រោមៈ

| ចំនួនករណី | ចំនួនជនរងគ្រោះ នីតិជន ប្រុស | ចំនួនជនរងគ្រោះ នីតិជន ស្រី | ចំនួនជនរងគ្រោះ អនីតិជន ប្រុស | ចំនួនជនរងគ្រោះ អនីតិជន ស្រី | ចំនួនជនរងគ្រោះ ជនបរទេស ប្រុស | ចំនួនជនរងគ្រោះ ជនបរទេស ស្រី | ចំនួនជនជាប់ចោទ នីតិជន ប្រុស | ចំនួនជនជាប់ចោទ នីតិជន ស្រី | ចំនួនជនជាប់ចោទ អនីតិជន ប្រុស | ចំនួនជនជាប់ចោទ អនីតិជន ស្រី | ចំនួនជនជាប់ចោទ ជនបរទេស ប្រុស | ចំនួនជនជាប់ចោទ ជនបរទេស ស្រី | ចំនួនជនជាប់ចោទ អញ្ញាតជន |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| សរុប ២៨០ | ៥៣ | ១០៦ | ៥៩ | ៩៨ | ០៥ | ០២ | ២៩៤ | ៣៩ | ១០ | ០ | ០២ | ០១ | ០២ |
| | ១៥៩ | | ១៥៧ | | ០៧ | | ៣៣៣ | | ១០ | | ០៣ | | ០២ |
| | ៣២៣ នាក់ | | | | | | ៣៤៨ នាក់ | | | | | | |

| ចំនួនករណី | បញ្ជូនទៅជំនុំជម្រះ | ផ្ទេរសមត្ថកិច្ច | ប្រកាសសាលក្រម រួចផុតបទចោទ សំណុំរឿង | រួចផុតបទចោទ ចំនួនមនុស្ស សរុប | រួចផុតបទចោទ ចំនួនមនុស្ស ស្រី | ផ្តន្ទាទោស ពិន័យជាប្រាក់ | ផ្តន្ទាទោស ដាក់ពន្ធនាគារ | ផ្តន្ទាទោស ចំនួនមនុស្ស សរុប | ផ្តន្ទាទោស ចំនួនមនុស្ស ស្រី | ទោសព្យួរ ទោសព្យួរសាកល្បង | ទោសព្យួរ ទោសព្យួរធម្មតា | ទោសព្យួរ ចំនួនមនុស្ស សរុប | ទោសព្យួរ ចំនួនមនុស្ស ស្រី | បណ្តឹងឧបាស្រ័យ បណ្តឹងទាស់ | បណ្តឹងឧបាស្រ័យ បណ្តឹងឧទ្ធរណ៍ | សរុបចាត់ការរួច | រឿងកំពុងចាត់ការ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| សរុប ២៨០ | ១២៤ | ០១ | ១២ | ០៨ | ០៥ | ០៤ | ៧២ | ៥៧ | ១០ | ០១ | ០៦ | ០២ | ០២ | ០ | ០២ | ១២៥ | ១៥៥ |
| | | | | | | | | | | | | | | | | ២៨០ សំណុំរឿង | |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និង ផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

#### ១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់

• **ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ** តាមរយៈស្ថានតំណាងនៅបរទេស បានសង្គ្រោះ ឧបត្ថម្ភ និងជួយសម្រួលដល់ការធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋខ្មែរ ដែលត្រូវបានកំណត់អត្តសញ្ញាណបឋម រកភាពរងគ្រោះ និងបានធ្វើការសន្និដ្ឋានបឋមថា សង្ស័យជាករណីស្នាក់នៅ និងធ្វើការងារដោយខុសច្បាប់ សរុបចំនួន **៧.១៨៣**នាក់(ស្រី **៣.២៦៣**នាក់) ក្នុងនោះសង្ស័យថា រងគ្រោះដោយអំពើជួញដូរមនុស្ស **៧៨**នាក់(ស្រី **៧៧**នាក់) ដូចមានក្នុងតារាងខាងក្រោមៈ

| ល.រ. | ប្រទេសគោលដៅ | មូលហេតុនៃការវិលត្រឡប់ | សរុប | ស្រី |
|---|---|---|---|---|
| ១ | ម៉ាឡេស៊ី | ពលករខុសច្បាប់ | ៣២ | ០៨ |
| ២ | ឥណ្ឌូនេស៊ី | ពលករខុសច្បាប់ | ០២ | ០០ |
| ៣ | ចិន | សង្ស័យជួញដូរ និងចាញ់បោកមេខ្យល់ | ៧៨ | ៧៧ |
| ៤ | សឹង្ហបុរី | ទ្រាំការងារមិនបាន | ០១ | ០១ |
| ៥ | វៀតណាម | ឆ្លងដែនខុសច្បាប់ | ១២ | ០៨ |

| | | | | |
|---|---|---|---|---|
| ៦ | ថៃ | ពលករខុសច្បាប់ | ៧.០៥៣ | ៣.១៦៨ |
| ៧ | ឡាវ | ឆ្លងដែនខុសច្បាប់ | ០៥ | ០១ |
| សរុប | | | ៧.១៨៣ នាក់ | ៣.២៦៣ នាក់ |

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានា សរុបចំនួន ៨១.៨១៥នាក់(ស្ត្រី ៣៣.៤២៥នាក់) កុមារ ៥.២៥៧នាក់ (កុមារី ៤.៧៩៦នាក់)សកម្មភាពមានដូចជា៖

- នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ នៃក្រសួង ស.អ.យ បាន ទទួល ជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានា សរុប ១៦១នាក់(ស្ត្រី ១២៣នាក់ កុមារា ០២កុមារី ០៧នាក់) មកពីប្រទេសចិន ១១០នាក់ ម៉ាឡេស៊ី ៣៩នាក់ វៀតណាម ០៧នាក់ ថៃ ០៤នាក់ និងនីហ្សេរីយ៉ា ០១នាក់ ***(ករណីអាពាហ៍ពិពាហ៍ផ្ទុយពី ឆន្ទៈ/បង្ខំ ១០២នាក់ កេងប្រវ័ញ្ចកម្លាំងពលកម្ម ២១នាក់ ជួញដូរកម្លាំងពលកម្ម ១៤នាក់ ជួញដូរផ្លូវភេទ ០៣នាក់ ពរពោះ ០២នាក់ ងាយរងគ្រោះ ១៨នាក់ និងសង្ស័យថាជាមេខ្យល់ ០១នាក់)*** បានសម្ភាសន៍កំណត់អត្តសញ្ញាណ រួចបញ្ជូនទៅទទួលសេវាបន្តនៅអង្គការដៃគូ។
- **មណ្ឌលសំចតប៉ោយប៉ែត** បានទទួលពីប្រទេសថៃចំនួន ៨១.៦៥៤នាក់ (ស្ត្រី ៣៣.៣០២នាក់ កុមារ ៥.២៥៥នាក់ កុមារី ៤.៧៨៩នាក់) បានសម្ភាសន៍កំណត់អត្តសញ្ញាណរកមុខសញ្ញាជនរងគ្រោះ ដូចជាៈ ករណីជួញដូរកម្លាំងពលកម្ម ០២នាក់ ករណីជួញដូរកម្លាំងពលកម្ម និងងាយរងគ្រោះ ៣៦១នាក់ (ស្ត្រី ១២៨នាក់ កុមារ ៣៤នាក់ (កុមារី ២៦នាក់) និងកុមារមិនមានមនុស្សអមដំណើរមកជាមួយដោយផ្តល់ការស្នាក់នៅរយៈពេលខ្លីចំនួន ៥៦នាក់ (កុមារា ២៩នាក់ កុមារី ២៧នាក់) មុនពេលបញ្ជូនទៅទទួលសេវាបន្តនៅអង្គការដៃគូ និងបញ្ជូនទៅសហគមន៍វិញ។

- **អគ្គស្នងការដ្ឋាននគរបាលជាតិ**
  - **នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន** បានទទួល និងសម្ភាសន៍ជនរងគ្រោះ ដែលបាន វិលត្រឡប់មកពីក្រៅប្រទេស ចំនួន ៩៨នាក់(ស្រី ៨៣នាក់) អនីតិជន ០៥នាក់ និង(បាន **សម្ភាសន៍**តាមអនឡាញចំនួន៨០នាក់(ស្រី ៦៨នាក់)អនីតិជន ០៤នាក់) មកពីប្រទេសចិន ៧៤នាក់(ស្រី) អនីតិជន ០៥នាក់ និងម៉ាឡេស៊ី ២៤នាក់ (ស្រី ០៩នាក់)។ ជាលទ្ធផល៖
    - ✓ រងគ្រោះដោយអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈចំនួន ៥៦នាក់(ស្រី) អនីតិជន ០៤នាក់ (ចិន)
    - ✓ រងគ្រោះដោយការស្នាក់នៅដោយខុសច្បាប់ចំនួន ៣៨នាក់(ស្រី ២៤នាក់) ក្នុងនោះ (ចិន ១៨នាក់(ស្រី)អនីតិជន ០១នាក់ និងម៉ាឡេស៊ី ២០នាក់(ស្រី ០៦នាក់)។
    - ✓ រងគ្រោះដោយកេងប្រវ័ញ្ចប្រាក់ឈ្នួលនៅម៉ាឡេស៊ី ០៣នាក់(ស្រី) និងមិនរងគ្រោះ ០១នាក់។ ជនរងគ្រោះខាងលើទៅតាមរយៈមេខ្យល់ផ្សេងៗគ្នា មិនស្គាល់អត្តសញ្ញាណ បច្ចុប្បន្នប្រគល់ឱ្យមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីស្តារនីតិសម្បទា។

- **ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត** ស្នងការដ្ឋាននគរបាលខេត្ត ចំនួន ០៥ បានទទួល និងសម្ភាសន៍ពលករខ្មែរ ដែលអាជ្ញាធរបរទេសចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ ក្នុងនោះមាន(ច្រកចាំយាម ច្រកជម្មជាតិ ច្រកអូរបីជាន់ ច្រកម៉ាឡៃ ច្រកបឹងត្រកួន និងច្រកអន្តរជាតិប៉ោយប៉ែត) និងច្រកទ្វារព្រំដែនអន្តរជាតិ កម្ពុជា-វៀតណាម បានចំនួន ១៩២លើក សរុបមនុស្សចំនួន **២៣.២៤៧**នាក់(ស្រី ៧.២២៨នាក់) អនីតិជន ២.៦៩១នាក់ ក្នុងនោះមាន៖
  - ○ **ខេត្តបន្ទាយមានជ័យ** ចំនួន១៥០លើក មនុស្សចំនួន ១៨.៦១១នាក់ (ស្រី ៥.៥៥០នាក់) អនីតិជន ២.១២៧នាក់។

- **ខេត្តបាត់ដំបង** ចំនួន ០១លើក មនុស្សចំនួន ១៥០នាក់ (ស្រី ៥៧នាក់) អនីតិជន ១៣នាក់។
- **ខេត្តកោះកុង** ចំនួន ២៥លើក មនុស្សចំនួន ៧៩២នាក់(ស្រី ១៩១នាក់ អនីតិជន ៩៧នាក់)។
- **ខេត្តប៉ៃលិន** ចំនួន ១៥លើក មនុស្សចំនួន ៣.៦៨៩នាក់ (ស្រី១.៤២៥នាក់) អនីតិជន ៤៥៤នាក់។
- **ខេត្តស្វាយរៀង** ចំនួន ០២លើក មនុស្សចំនួន ០៥នាក់ (ស្រី ០៥នាក់)។

**១.២. ការទទួលសាកសពបញ្ជូនត្រឡប់**

- **ការិយាល័យទំនាក់ទំនងព្រំដែនកម្ពុជា-ថៃ នៃគណៈកម្មាធិការព្រំដែនទូទៅកម្ពុជា-ថៃ** បានទទួលសពពលរដ្ឋមកពីប្រទេសថៃ បានចំនួន ៤៤សព(ស្រី ០៩សព)។

**២. ការផ្តល់សេវា និងការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស**

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្សទៅស្តារនីតិសម្បទានៅមណ្ឌលរបស់អង្គការដៃគូ សរុប ១.៦៩៦នាក់(ស្រ្តី ៥៨១នាក់ កុមារា ៤២០នាក់ កុមារី ៦៦៣នាក់) ក្នុងនោះករណី(*អាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈ/បង្ខំ ៣៧នាក់ កេងប្រវ័ញ្ចកម្លាំងពលកម្ម ១៥៨នាក់ ជួញដូរកម្លាំងពលកម្ម ០៦នាក់ ជួញដូរផ្លូវភេទ ៤៨៧នាក់ រំលោភបំពានផ្លូវភេទ ៣៣៦នាក់ សញ្ចារកម្ម ១៨នាក់ និងងាយរងគ្រោះ ៦៥៤នាក់*)។ ក្នុងនោះ *មន្ទីរស.អ.យ រាជធានី ខេត្ត ចំនួន ០៨នាក់ និងអង្គការដៃគូ ចំនួន ១.៦៨៨នាក់*។

**៣. ការធ្វើសមាហរណកម្មជនរងគ្រោះ និងជនងាយរងគ្រោះ**

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ សមាហរណកម្ម ជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និងរំលោភបំពានផ្លូវភេទ ត្រឡប់ទៅសហគមន៍វិញសរុប ៣៧នាក់(ស្រី ២២នាក់) កុមារី ០១នាក់ ក្នុងនោះ *(ករណីអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈ/បង្ខំ ២០នាក់ ជួញដូរកម្លាំងពលកម្ម ១៤នាក់ និងករណីជួញដូរផ្លូវភេទ ០៣នាក់)*។
  - ➢ និងត្រូវបានធ្វើមាតុភូមិនិវត្តន៍ជនជាតិភូមាទៅប្រទេសដើមវិញសរុបចំនួន ០៩នាក់ (បុរស) ជាករណីកេងប្រវ័ញ្ចកម្លាំងពលកម្ម ដោយមានកិច្ចសហការចូលរួមពីអ្នកពាក់ព័ន្ធ និងអង្គការដៃគូ ដូចជា (អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ(IJM) និងអង្គការកោរីតាសកម្ពុជា)។
- **ការិយាល័យទំនាក់ទំនងព្រំដែនកម្ពុជា-ថៃ នៃគណៈកម្មាធិការព្រំដែនទូទៅកម្ពុជា-ថៃ** បានធ្វើសមាហរណកម្មជនជាតិវៀតណាម(ករណីស្នាក់នៅប្រទេសកម្ពុជាដោយខុសច្បាប់) ចំនួន ៣៩នាក់(ស្រី ០៦នាក់) មាតុភូមិនិវត្តន៍ទៅប្រទេសខ្លួនវិញ។

## III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

**១. ការងារបណ្តុះបណ្តាល**

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ) បានសហការជាមួយក្រសួង ស្ថាប័ន អង្គការដៃគូពាក់ព័ន្ធ រៀបចំបើកវគ្គបណ្តុះបណ្តាលចំនួន ១៧០វគ្គ មានសិក្ខាកាមចូលរួមចំនួន ៦.៦៥៨នាក់ ក្នុងនោះមានស្ត្រី ២.៤៧៤នាក់ ដើម្បីពង្រឹងសមត្ថភាពគ្រូបង្គោល មន្ត្រីអនុវត្តច្បាប់ និងសមាជិក គ.រ.ប.ជ/គ.ខ.ប.ជ ដូចមានក្នុងតារាងខាងក្រោម៖

| |
|---|
| ថ្នាក់ជាតិមាន ក្រសួង ស្ថាប័ន និងថ្នាក់ក្រោមជាតិមាន រាជធានី-ខេត្ត (គ.រ.ប.ជ/គ.ខ.ប.ជ) ដែលមាននាយកដ្ឋាន មន្ទីរ អង្គភាពពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូមាន៖ អង្គការសម្ព័នចាប់ដៃ, ស្ថានទូតអាមេរិក(FBI) អង្គការសកម្មភាពដើម្បីកុមារ(APLE), អង្គការ IOM, អង្គការមូលនិធិអេ២១, អង្គការមេត្រីអន្តរជាតិ(AIM SWAT), អង្គការវីនរ៉ក់, អង្គការយូនីសេហ្វ Unicef, អង្គការ UNFPA , អង្គការមូលនិធិឋាហាការអន្តរជាតិ, អង្គការ ASEAN-ACT, អង្គការបេសកកម្មយុត្តិធម៌(IJM), អង្គការជីវិតនៅកម្ពុជា (TLC), អង្គការម្លប់ឬស្សី, អង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី |

(LSWCW), អង្គការម៉ារីតាន់ភីស បានរៀបចំបើកវគ្គបណ្តុះបណ្តាលទាំងទ្រឹស្តី និងការអនុវត្តកសាងសមត្ថភាព ដោយផ្ទាល់ និងតាមប្រព័ន្ធ Zoom ដល់៖ អ្នកផ្តល់ប្រឹក្សាយោបល់ អ្នកធ្វើការងារនៅមណ្ឌលធនធានពលករទេសន្តរប្រវេសន៍ (MRC) គ្រូបង្គោល (ថ្នាក់តំបន់) នាយនគរបាល នៃស្នងការនគរបាលរាជធានី-ខេត្ត អាជ្ញាធរ ក្រុង/សង្កាត់/ភូមិ/ឃុំ/ស្រុក ស្តីពី៖

១-ណែនាំតម្រង់ទិសពលករមុនពេលចេញដំណើរទៅបរទេស។ ២-ការត្រៀមលក្ខណៈសម្បត្តិក្នុងការស្វែងរកការងារធ្វើចំនួន។ ៣-ជំនាញទន់។ ៤-នីតិវិធីនៃការចុះយុទ្ធនាការផ្សព្វផ្សាយទប់ស្កាត់ ការប្រើប្រាស់ពលកម្មកុមារក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ និងកសិឧស្សាហកម្ម។ ៥-ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ ការធ្វើអាជីវកម្មផ្លូវភេទ និងអំពើហិង្សាលើស្ត្រី និងកុមារ ការកេងកម្លាំងពលកម្ម ការធ្វើចំណាកស្រុកខុសច្បាប់ និងកិច្ចការពារកុមារ ដើម្បីពង្រឹងដល់មន្ត្រីមន្ទីរនានាដែលពាក់ព័ន្ធ និងផ្សព្វផ្សាយដល់ប្រជាពលរដ្ឋទូទាំងប្រទេស។ ៦-កិច្ចការពារជនរងគ្រោះ និងគោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បី ផ្តល់សេវាសមស្របដើម្បីពង្រឹងដល់មន្ត្រី ស.អ.យ ក្រុង/ស្រុក/ខេត្ត។ ៧-ការកំណត់អត្តសញ្ញាណជនរងគ្រោះ និងនីតិវិធីស៊ើបអង្កេតករណីជួញដូរមនុស្ស។ ៨-ការគាំទ្រដល់កុមាររងគ្រោះ និងបច្ចេកទេសក្នុងការធ្វើការជាមួយកុមារក្នុងនិតិវិធីព្រហ្មទណ្ឌនិងការឆ្លើយតបបទល្មើសផ្លូវភេទលើកុមារ។ ៩-សេចក្តីណែនាំអំពីការស៊ើបអង្កេតអំពើកេងប្រវ័ញ្ចកុមារ។ ១០-ការគ្រប់គ្រង និងការបញ្ជូនករណីជនរងគ្រោះដោយអំពើជួញដូរមនុស្សទៅកាន់សេវាគាំទ្រ។ ១១-ការមិនបង្ករហានិភ័យ និងការគ្រប់គ្រងករណីសម្រាប់ពលករ នៅតាមភូមិ/ឃុំ/ស្រុក។ ៦-កិច្ចការពារកុមារ និងការទប់ស្កាត់ការធ្វើអាជីវកម្មផ្លូវភេទលើកុមារ ដល់ក្រុមអ្នកស្ម័គ្រចិត្ត ដឹកនាំកុមារលេងកម្សាន្តនៅតាមសហគមន៍។ ១២-ស្តីពីនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងការសម្ភាសបែបកោសល្យវិច័យ ដល់មន្ត្រីសង្គមកិច្ច មន្ត្រីការិយាល័យជំនាញ មន្ត្រីនគរបាលក្រុង/ស្រុក។ ១៣-ការគ្រប់គ្រងករណីដល់ក្រុមការងារថ្នាក់ខេត្ត ក្រុង និងស្រុក។ ១៤-កិច្ចការពារកុមារ និងច្បាប់ស្តីពីយុត្តិធម៌អនីតិជន។ ១៥-ការកំណត់និងឆ្លើយតបបែបកុមារមេត្រីទៅនឹងបទល្មើសផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិត ដល់មន្ត្រីពាក់ព័ន្ធនៅក្រុង/ស្រុក។ ១៦-បណ្តាញកិច្ចការពារកុមារ ដល់មន្ត្រីផ្តល់សេវាសង្គមកិច្ច និងអ្នកពាក់ព័ន្ធថ្នាក់ឃុំ សង្កាត់ ដល់សមាសភាព គ.ក.ន.ក ក្រុង/ស្រុក។ ១៧-កិច្ចការពារផ្លូវច្បាប់សម្រាប់សិទ្ធិស្ត្រី និងកុមារនៅកម្ពុជា។ ១៨-ការអង្កេតសញ្ញាណនៃការប៉ះទង្គិចផ្លូវចិត្តទៅលើជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ ១៩-វិធានការបង្វែរអនីតិជនជំទាស់នឹងច្បាប់ដល់អភិបាល ស្រុកទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មន្ត្រីនគរបាលយុត្តិធម៌ និងមន្ត្រីសង្គមកិច្ច និងសុខុមាលភាពសង្គម ក្រុង/ស្រុក។ ២០-ស្តីពីសុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញ និងការទប់ស្កាត់បឋម។ ២១-បទប្បញ្ញត្តិពាក់ព័ន្ធនឹងទេសន្តរប្រវេសន៍ ដើម្បីស្វែងរកការងារប្រកបដោយសុវត្ថិភាព ការជ្រើសរើសប្រកបដោយក្រមសីលធម៌ និងសេវាកម្មដែលឆ្លើយតបនឹងយេនឌ័រ។

| សកម្មភាពរៀបចំវគ្គបណ្តុះបណ្តាល របស់ក្រសួងស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអង្គការដៃគូ | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំវគ្គបណ្តុះបណ្តាល | ៦៨ | ៣.២០១ | ១.០២៦ |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ០៤ | ២១៨ | ៨៣ |
| ក្រសួងកិច្ចការនារី | ០១ | ៥៦ | ៤២ |
| អគ្គស្នងការដ្ឋាននគរបាលជាតិ | ១៤ | ៧២១ | ១៤៦ |
| អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស | ០៣ | ១០៩ | ៤២ |
| អង្គការម៉ារីតាន់ភីស(ខេត្តបាត់ដំបង) | ០៣ | ៩៥ | ០០ |
| ខេត្តបន្ទាយមានជ័យ | ០១ | ១១៦ | ៤៧ |
| ខេត្តបាត់ដំបង | ០១ | ៣២ | ០៣ |
| ខេត្តសៀមរាប | ១៣ | ៤៩១ | ១៥៣ |
| ខេត្តព្រះវិហារ | ០១ | ៣៨ | ១៧ |
| ខេត្តស្វាយរៀង | ៣៧ | ៧២៤ | ៤០៥ |
| ខេត្តតាកែវ | ០៨ | ៤០៦ | ៣១៦ |
| ខេត្តរតនគីរី | ០៣ | ៦២ | ៣៤ |
| ខេត្តកំពង់ចាម | ០៣ | ១១៦ | ៣៨ |
| ខេត្តត្បូងឃ្មុំ | ០២ | ៩១ | ២៤ |
| ខេត្តព្រៃវែង | ០៣ | ៥១ | ២៩ |

| | | | |
|---|---|---|---|
| ខេត្តព្រះសីហនុ | ០១ | ០៥ | ០១ |
| ខេត្តកំពត | ០១ | ១៧ | ០០ |
| ខេត្តកំពង់ឆ្នាំង | ០៣ | ១០៩ | ៦៩ |
| សរុប | **១៧០** វគ្គ | **៦.៦៥៨** នាក់ | **២.៨៧៤**នាក់ |

## ២. សិក្ខាសាលា

▪ ថ្នាក់ជាតិ

• **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានសហការរៀបចំសិក្ខាសាលាស្តីពី៖

○ផែនការអាជីព និងជ្រើសរើសជំនាញសម្រាប់សិស្សមធ្យមសិក្សាទុតិយភូមិចំនួន **២៦២**វគ្គ ដែលមានអ្នកចូលរួមសរុបចំនួន **១៣.២១០**នាក់(ស្រី **៦៧៥**នាក់)។

○ការណែនាំអាជីពការងារ និងវិជ្ជាជីវៈសម្រាប់សិស្ស និស្សិតនៅគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងសាកលវិទ្យាល័យចំនួន **២០**វគ្គ ដែលមានអ្នកចូលរួមសរុប **៩៩៧**នាក់។

○ការផ្សព្វផ្សាយ និងប្រមូលអ្នកស្វែងរកការងារធ្វើនៅតាមមូលដ្ឋានចំនួន **៣១**វគ្គ ដែលមានអ្នកចូលរួមសរុបចំនួន **១.៥៤០**នាក់(ស្រី **៥៨២**នាក់)។

○ការផ្សព្វផ្សាយថ្នាក់ជាតិ និងការចែករំលែកបទពិសោធន៍ពីកម្មវិធី SaverAsia( សេវាឌីជីថលក្នុងការលើកកម្ពស់សុវត្ថិភាពផ្នែកហិរញ្ញវត្ថុ សម្រាប់ពលករទេសន្តរប្រវេសន៍) ដោយមានការសហការជាមួយអង្គការ ILO។

○ការណែនាំសៀវភៅភាសាជប៉ុន អ៊ីរ៉ូដូរី និងតេស្តភាសាជប៉ុន JFT-Basic ក្នុងគម្រោងពលករជំនាញកម្ពុជាទៅប្រទេសជប៉ុន នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

• **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** បានសហការជាមួយអង្គការរតៈអ៊ីនធើណេសិនណល និងគម្រោងកម្មវិធី ASEAN-ACT និងអង្គការមូលនិធិអេ ២១ រៀបចំសិក្ខាសាលាចំនួន **០២**លើក ក្រោមអធិបតីភាពឯកឧត្តម **ញឹក វណ្ណារ៉ា** រដ្ឋលេខាធិការក្រសួងស.អ.យ ដូចជាសិក្ខាសាលា៖

○ពិគ្រោះយោបល់ចុងក្រោយ លើការធ្វើបច្ចុប្បន្នភាពសារាចរណែនាំ ០០៩និងទម្រង់ គ្រប់គ្រងជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដោយមានការចូលរួមពីមន្ត្រីពាក់ព័ន្ធនៃក្រសួងស.អ.យ មន្ទីរ ស.អ.យ រាជធានី-ខេត្ត និងអង្គការដៃគូមិនមែនរដ្ឋាភិបាល សរុបចំនួន **១១០**នាក់ (ស្រី **៣៧**នាក់)នៅសណ្ឋាគារ ប្រេស៊ីដង់ ខេត្តបាត់ដំបង។

○កែសម្រួលចុងក្រោយលើនីតិវិធី ស្តីពីដំណើរមោតុភូមិនិវត្តន៍ជនរងគ្រោះ និងជនសង្ស័យថារងគ្រោះ ដោយអំពើជួញដូរមនុស្ស ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីជំនាញពីក្រសួង ស្ថាប័ន នាយកដ្ឋាន មន្ទីរ ស.អ.យ និងអង្គការដៃគូមិនមែនរដ្ឋាភិបាល សរុបចំនួន **៤៦**នាក់ (ស្រី **១៣**នាក់) នៅមន្ទីរ ស.យ.អ ខេត្តព្រះសីហនុ។

• **ក្រសួងកិច្ចការនារី** បានសហការជាមួយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) រៀបចំសិក្ខាសាលាស្តីពីការអនុវត្តរបស់កម្ពុជា លើផែនការសកម្មភាពមហាអនុតំបន់មេគង្គខមមីតទី៤ និងការពិគ្រោះយោបល់ថ្នាក់ជាតិ លើកទី១ លើការរៀបចំយន្តការបញ្ជូនឆ្លងដែន ក្រោមអធិបតីភាពដ៏ខ្ពស់ **លោក ជំទាវ កិត្តិបណ្ឌិត អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី** នៅសណ្ឋាគារកាំបូឌីយ៉ាណា ដែលមានអ្នកចូលរួមពីក្រសួង ស្ថាប័ន សភាពជីរ៉ុបប្រចាំនៅកម្ពុជា កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិប្រចាំកម្ពុជា និងថ្នាក់តំបន់ ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលសរុបចំនួន **៧១**នាក់(ស្រី **៣៩**នាក់)។

• **ក្រសួងទេសចរណ៍** បានរៀបចំសិក្ខាសាលាស្តីពី "សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍" ចំនួន ០២លើក នៅខេត្តកំពង់ស្ពឺ និងខេត្តតាកែវ ដែលមានសិក្ខាកាមចូលរួមជាម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន បៀហ្គាឌិន ម៉ាស្សា ខារ៉ាអូខេ និងរមណីយដ្ឋានទេសចរណ៍ សរុបចំនួន **១១២**នាក់ (ស្រី **៤២**នាក់ )។

- **ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍** សហការជាមួយអង្គការ UNICEF Cambodia បានរៀបចំសិក្ខាសាលា ស្តីពី «ការជំរុញការចូលរួមរបស់ក្រុមហ៊ុនបច្ចេកវិទ្យាក្នុងកិច្ចការពារកុមារលើប្រព័ន្ធអនឡាញ» ក្រោមអធិបតីភាព ឯកឧត្តម **ផុន វ៉ាត** រដ្ឋលេខាធិការក្រសួង និងមានការចូលរួមពីសំណាក់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្រុមហ៊ុនបច្ចេកវិទ្យា ប្រតិបត្តិករទូរគមនាគមន៍ក្នុងស្រុក អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល អ្នកអនុវត្តច្បាប់ សរុបប្រមាន **១៥០**នាក់។
- **អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** បានរៀបចំសិក្ខាសាលាចំនួន ០២លើក៖
  - សិក្ខាសាលាថ្នាក់ជាតិ ស្តីពីការរៀបចំផែនការជាតិ សម្រាប់អនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ ដែលរៀបចំដោយអង្គការ IOM មានសិក្ខាកាមចូលរួមចំនួន **៥៥**នាក់ (ស្រី **១៦**នាក់) នៅសណ្ឋាគារកាំបូឌីយ៉ាណា។
  - សិក្ខាសាលា កិច្ចប្រជុំពិនិត្យពិភាក្សា លើកទី២ និងធ្វើបច្ចុប្បន្នភាពសៀវភៅគោលការណ៍ណែនាំស្តីពីបែបបទ និងនីតិវិធី នៃការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប សិក្ខាកាមចូលរួមចំនួន **៥២**នាក់ (ស្រី ០៨នាក់) ដោយមានកិច្ចសហការគាំទ្រពីអង្គការ Asian ACT នៅសណ្ឋាគារស៊ាន់វ៉េភ្នំពេញ។
- **អង្គការ We World** បានសហការជាមួយ ក្រុមការងារលេខាធិការដ្ឋាន ក្រុមការងារកិច្ចការអនុវត្តច្បាប់ និងក្រុមការងារកិច្ចការទេសន្តរប្រវេសន៍ ខេត្តសៀមរាប៖ រៀបចំសិក្ខាសាលាបិទបញ្ចប់គម្រោងសិទ្ធិការងារ"លើកកម្ពស់សិទ្ធិការងាររបស់ពលករចំណាកស្រុកកម្ពុជា ដែលមានជំនាញទាបនៅក្នុងប្រទេសថៃ" បានចំនួន **០១**លើក នៅរាជធានីភ្នំពេញ។
- **អង្គការ PLAN International, Cambodia ACTs និងអង្គការបន្ទាយស្រី** សហការជាមួយលេខាធិការដ្ឋានគ.ខ.ប.ជខេត្តសៀមរាប បានរៀបចំសិក្ខាសាលា ស្តីពី «បិទបញ្ចប់ដំណើរការគម្រោងបញ្ឈប់ការកេងប្រវ័ញ្ចលើកុមារ តាមរយៈការទទួលបានសេវាសមស្រប» រយៈពេល០១ថ្ងៃ នៅសណ្ឋាគារប៉ាវ៉ាដាយ ខេត្តសៀមរាប មានសមាសភាពចូលរួមជា តំណាងមកពីក្រសួងអប់រំ យុវជន និងកីឡា អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ មន្ទីរពាក់ព័ន្ធ និងក្រុមក្លឹបកុមារ មកពីខេត្តសៀមរាប និងបាត់ដំបង សរុបចំនួន **៥៧**នាក់ (ស្រី **៣៦**នាក់)។

▪ **ថ្នាក់ក្រោមជាតិ**

- **ខេត្តកណ្តាល៖** អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក) បានសហការជាមួយអង្គការហាការ (HAGAR) រៀបចំសិក្ខាសាលា ស្តីពីសិទ្ធិកុមារ កិច្ចការពារកុមារ និងច្បាប់នានាដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារ ចំណាកស្រុកដោយសុវត្ថិភាព និងការជួញដូរមនុស្ស ក្រោមអធិបតីភាពលោកជំទាវ **ហ៊ុន កុសនី** អភិបាលរងនៃគណៈអភិបាលខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ នៅសាលប្រជុំសាលាខេត្តកណ្តាល(អគារC) មានចូលរួមសរុបចំនួន **៥៣**នាក់ ស្រី **៣៤**នាក់។
- **ខេត្តស្វាយរៀង៖** ស្នងការដ្ឋាននគរបាលខេត្ត សហការជាមួយអង្គការហាការ (HAGAR) បើកសិក្ខាសាលា ស្តីពីសិទ្ធិកុមារ និងច្បាប់នានាពាក់ពន្ធ័នឹងកិច្ចការពារកុមារ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងការជួញដូរមនុស្ស **០១**លើក មានសិក្ខាកាមចំនួន **៥៤**នាក់(ស្រី **៣៧**នាក់)។
- **ខេត្តបាត់ដំបង៖** សហការជាមួយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងអង្គការ ASEAN-ACT រៀបចំសិក្ខាសាលាស្តីពី កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស **០១**លើក នៅស្រុកសំពៅលូន មានសិក្ខាកាមចំនួន **៧៤**នាក់ ស្រី **៤២**នាក់។
- **ខេត្តតាកែវ៖** មន្ទីរទេសចរណ៍ខេត្ត បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីសុវត្ថិភាពកុមារ ក្នុងវិស័យទេសចរណ៍ ជូនដល់អាជីវករ សេវាករទេសចរណ៍ នៅក្នុងក្រុងដូនកែវ ចំនួន **០១**លើក អ្នកចូលរួមចំនួន **៤៥**នាក់ (ស្រី **១៨**នាក់)។
- **ខេត្តព្រៃវែង៖** មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយអង្គការហាការ បានរៀចំសិក្ខាសាលា ស្តីពីចំណាកស្រុកដោយសុវត្ថិភាព និងការទប់ស្កាត់អំពើជួញដូរមនុស្ស នៅស្រុកកំពង់ត្របែក និងស្រុកព្រះស្តេច មានអ្នកចូលរួមចំនួន **៦០**នាក់។

## ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ១. កិច្ចប្រជុំក្នុងប្រទេស និងក្រៅប្រទេស

#### ១.១.កិច្ចប្រជុំក្នុងប្រទេស

- ថ្នាក់ជាតិ

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ) បានសហការជាមួយក្រសួង ស្ថាប័ន អង្គការដៃគូពាក់ព័ន្ធ បានដឹកនាំក្រុមការងារ និងរៀបចំកិច្ចប្រជុំបានចំនួន **១៧៣**លើក មានអ្នកចូលរួមចំនួន **៤.៨៥៥**នាក់ ក្នុងនោះមានស្ត្រី **២.៤៨៧**នាក់ ដើម្បីពង្រឹងសមត្ថភាពគ្រូបង្គោល មន្ត្រីអនុវត្តច្បាប់ និងសមាជិក គ.រ.ប.ជ/គ.ខ.ប.ជ ដូចមានក្នុងតារាងខាងក្រោម៖

<table>
<tr><td colspan="4">ថ្នាក់ជាតិមាន ក្រសួង ស្ថាប័ន និងថ្នាក់ក្រោមជាតិមាន រាជធានី-ខេត្ត (គ.រ.ប.ជ/គ.ខ.ប.ជ) ដែលមាននាយកដ្ឋាន មន្ទីរ អង្គភាពពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូមាន៖ អង្គភាពការពារកុមារ CPU, South Asia, IOM, Asean-Act, សហគមន៍អឺរ៉ុប បានរៀបចំកិច្ចប្រជុំពិភាក្សា ដោយផ្ទាល់ និងតាមប្រព័ន្ធ Zoom ដើម្បីបង្រឹងសមត្ថភាពការងារដល់មន្ត្រីពាក់ព័ន្ធ ថ្នាក់អគ្គ នាយកដ្ឋាន លេខាធិការដ្ឋានរាជធានី-ខេត្ត និងអាជ្ញាធរ ក្រុង/សង្កាត់/ភូមិ/ឃុំ/ស្រុក ស្តីពី៖<br>១-ការសម្រួលខ្លឹមសាររបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២១ និងទិសដៅឆ្នាំ២០២២។ ២-បែបបទ និងនីតិវិធី នៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប។ ៣-ពិភាក្សាអំពីផែនការសកម្មភាពដែលត្រូវអនុវត្ត ដោយអង្គការដៃគូ លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២២។ ៤-ការធ្វើបទបង្ហាញពីសេវាកម្ម និងព័ត៌មាន នៃគំរោងមជ្ឈមណ្ឌល CASA យុទ្ធនាការគាំទ្រទិវាអន្តរជាតិ ដើម្បីសុវត្ថិភាពអ៊ីនធឺណិត។ ៥-"រួមគ្នាលើកកម្ពស់ ការពារ និងគោរពសិទ្ធិកុមារ តាមរយៈការប្រើប្រាស់ប្រព័ន្ធអនឡាញប្រកបដោយការទទួលខុសត្រូវ" ។ ៦-ករណីពពោះជំនួស។ ៧-«ការគ្រប់គ្រងព្រំដែន និងទេសន្តរប្រវេសន៍ការងារ នៅក្នុងបរិបទនៃការស្តារឡើងវិញបន្ទាប់ពីវិបត្តិកូវីដ-១៩»។ ៧-"កិច្ចសហការ សម្រាប់ការអនុវត្តគម្រោងបង្ការទប់ស្កាត់ភាពងាយរងគ្រោះនៃអំពើជួញដូរមនុស្ស"។ ៨-វឌ្ឍនភាពការងារ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ ៩-«គម្រោងអភិវឌ្ឍសមត្ថភាពភាសាបរទេស (ខ្មែរ-ថៃ) និងការចុះក្នុងតំបន់ ដើម្បីសួរសុខទុក្ខការអនុវត្តន៍គម្រោងនៅតាមសាលារៀនក្នុងខេត្តកោះកុង»។ ១០-ការងារសាងសង់មជ្ឈមណ្ឌលសំចត និងស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងជនងាយរងគ្រោះ។ ១១-វាយតម្លៃលទ្ធផលការងារ បញ្ហាប្រឈមឧបសគ្គ និងលើកផែនការបន្ត។ ១២-បូកសរុបរបាយការណ៍ប្រចាំខែ ត្រីមាស និងឆមាស ឆ្នាំ២០២២។ ១៣-ការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ ការធ្វើអាជីវកម្មផ្លូវភេទ។</td></tr>
<tr><td>សកម្មភាពរៀបចំកិច្ចប្រជុំ របស់ក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាកក្រោមជាតិ និងអង្គការដៃគូ</td><td>ចំនួនលើក</td><td>ចំនួនអ្នកចូលរួម</td><td>ចំនួនស្រី</td></tr>
<tr><td>គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស</td><td>១៥</td><td>១៥២</td><td>៥៣</td></tr>
<tr><td>ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា</td><td>០៥</td><td>៨៤</td><td>៤៩</td></tr>
<tr><td>ក្រសួងអប់រំ យុវជន និងកីឡា</td><td>០២</td><td>៣៥</td><td>១៨</td></tr>
<tr><td>ខេត្តបន្ទាយមានជ័យ</td><td>០១</td><td>១៥</td><td>១០</td></tr>
<tr><td>ខេត្តសៀមរាប</td><td>២០</td><td>១.០៩៩</td><td>២៧៩</td></tr>
<tr><td>ខេត្តព្រះវិហារ</td><td>០១</td><td>៣១</td><td>១០</td></tr>
<tr><td>ខេត្តក្រចេះ</td><td>០៥</td><td>៣០៣</td><td>២៤៤</td></tr>
<tr><td>ខេត្តកំពង់ចាម</td><td>០២</td><td>៥២</td><td>១៨</td></tr>
<tr><td>ខេត្តស្វាយរៀង</td><td>០១</td><td>៥៧</td><td>២៧</td></tr>
<tr><td>ខេត្តកណ្តាល</td><td>៤៤</td><td>១.៣៨៥</td><td>៧៣៩</td></tr>
<tr><td>ខេត្តព្រៃវែង</td><td>១៣</td><td>៤២១</td><td>១៨៣</td></tr>
<tr><td>ខេត្តកំពត</td><td>៥៩</td><td>១.១៣៦</td><td>៨២៤</td></tr>
<tr><td>ខេត្តកែប</td><td>០១</td><td>២៨</td><td>០៩</td></tr>
<tr><td>ខេត្តកំពង់ឆ្នាំង</td><td>០៤</td><td>៥៨</td><td>២៤</td></tr>
<tr><td>សរុប</td><td>១៧៣ លើក</td><td>៤.៨៥៥ នាក់</td><td>២.៤៨៧នាក់</td></tr>
</table>

### ១.២.កិច្ចប្រជុំក្រៅប្រទេស

- ថ្នាក់ជាតិ

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ** លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងជាអនុប្រធានក្រុមប្រឹក្សាជាតិដើម្បីកុមារ បានដឹកនាំ៖
  - គណៈប្រតិភូកម្ពុជាមាន០៦រូប ចូលរួមក្នុងកិច្ចប្រជុំ ការពារបាយកាណ៍ថ្នាក់ជាតិលើកទី៤ ទី៥ និងទី៦ ស្តីពី ការអនុវត្តអនុសញ្ញាសិទ្ធិកុមារក្នុងកិច្ចប្រជុំលើកទី៩០ របស់គណៈកម្មាធិការសិទ្ធិកុមារ (CRC) អង្គការសហប្រជាជាតិ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស។
  - គណៈប្រតិភូកម្ពុជា រួមដំណើរដោយ ឯកឧត្តម **ញឹក វណ្ណារ៉ា** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច និងតំណាងពីក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ តំណាងពីអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ដើម្បីចូលរួម ក្នុងវេទិកាអន្តរជាតិពិនិត្យឡើងវិញនូវការអនុវត្ត GCM ក្នុងនាមកម្ពុជាជាប្រទេស Champion Country នៅទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក។

## ២. ជំនួបពិភាក្សាការងារ

- ថ្នាក់ជាតិ

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ**
  - លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញទទួលជួបពិភាក្សាការងារជាមួយ៖ **១**-លោក **សុខ លាំង** អ្នកស្រាវជ្រាវឯករាជ្យ នៃវិទ្យាស្ថានឯករាជ្យក្រៅប្រទេស (ODI) ដែលមានទីតាំងនៅទីក្រុងឡុងប្រទេសអង់គ្លេស និងជាអ្នកសិក្សាស្រាវជ្រាវឱ្យកម្មវិធី ASEAN-ACT ចូលជួបសម្តែងការគួរសម និងអនុញ្ញាតឱ្យសួរសំណួរស្រាវជ្រាវមួយចំនួន ពាក់ព័ន្ធភាពងាយរងគ្រោះដោយអំពើជួញដូរមនុស្ស របស់ពលករចំណាកស្រុកកម្ពុជា នៅក្នុងបន្ទប់ការងាររបស់ លោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ។ **២**-លេខាស្ថានទូតអាមេរិកប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ពាក់ព័ន្ធនឹងករណីពពោះជំនួស។ **៣**-តំណាងអង្គការ UNICEF Mr. Benjamin, Wildfire Child Protection Specialist និង លោកស្រី ចាន់ កញ្ញា មន្ត្រីអភិវឌ្ឍន៍យុវជននិងវ័យជំទង់ ដើម្បីពិភាក្សាពីការពង្រីកកិច្ចសហការលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេសកិច្ចការពារកុមារជាជនរងគ្រោះ ងាយរងគ្រោះ និងការពង្រឹងក្រមសីលធម៌របស់មន្ត្រីនៅមណ្ឌល ចត្តាឡីស័ក ក៏ដូចជាមន្ត្រីពាក់ព័ន្ធការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ នៅក្នុងចំណោមពលករទេសន្តរប្រវេសន៍ ផ្តោតសំខាន់ស្ត្រីនិងកុមារ។ **៤**-តំណាងអង្គការ JICA ប្រចាំនៅកម្ពុជា ពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ០១លើក។ **៥**-ប្រធានតំណាងអង្គការវីនរ៉ក់ ស្តីអំពីកិច្ចសហប្រតិបត្តិការការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ០១លើក។ **៦**-ជំនួបជាមួយតំណាងម្ចាស់ជំនួយនៃអង្គការ ការីតាសស្វីស ដើម្បីសំណេះសំណាល និងស្វែងយល់ពីបច្ចុប្បន្នភាពនៃការអនុវត្តគម្រោងរបស់ខ្លួន ០១លើក។ **៧**-តំណាង និងសហការី របស់អង្គការសម្ព័ន្ធចាប់ដៃ នៅសាលប្រជុំ គ.ជ.ប.ជ ។ **៨**-អង្គការវីនរ៉ក់អន្តរជាតិ និងប្រគល់-ទទួល សៀវភៅរបាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិ ផែនយុទ្ធសាស្ត្រជាតិ៥ឆ្នាំ ២០១៩-២០២៣ នៅសាលប្រជុំ គ.ជ.ប.ជ។ **៩**-តំណាងអង្គការសេរីភាពកម្ពុជាអូស្ត្រាលីកំពុងតែអនុវត្ត និងស្វែងយល់បន្ថែមអំពីលទ្ធភាពបង្កើនកិច្ចសហប្រតិបត្តិការរវាង គ.ជ.ប.ជ ជាមួយនិង អង្គការសេរីភាពកម្ពុជាអូស្ត្រាលី។

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានជួបពិភាក្សាការងារជាមួយ៖
  - លោក POTTLER Maximilian នាយកគ្រប់គ្រងគម្រោងប្រចាំតំបន់ នៃអង្គការ IOM ដើម្បីសិក្សាលទ្ធភាពពង្រីកកិច្ចសហការក្រោមគម្រោង PROMISE ដំណាក់កាលទី២ ស្តីពីការកាត់បន្ថយភាពក្រីក្រតាមរយៈទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព ការអភិវឌ្ឍជំនាញ និងការលើកកម្ពស់

សេវាស្វែងរកការងារឱ្យធ្វើ ដើម្បីគាំពារ និងគាំទ្រដល់ពលករទេសន្តរប្រវេសន៍ក្នុងការត្រៀមចូលទីផ្សារការងារ ទទួលបាននូវឱកាសការងារសមរម្យ និងសុខុមាលភាពល្អប្រសើរ បន្ទាប់ពីវិលត្រឡប់ចូលមាតុភូមិវិញ។

- អង្គការ IOM លើ (១) គម្រោងបណ្តុះបណ្តាលវគ្គខ្លីដល់ពលករទេសន្តរប្រវេសន៍នៅកម្ពុជានិងចុះកម្មសិក្សាឬហាត់ការងារនៅប្រទេសថៃ (តាមម៉ូដែលនៃគម្រោង PROMISE ដំណាក់កាលទី១)។ (២) គម្រោងសហការជាមួយនឹងភ្នាក់ងារស្វែងរកការងារឱ្យធ្វើក្នុងស្រុក ដើម្បីផ្តល់ការបណ្តុះបណ្តាលវគ្គខ្លីដល់ពលករទេសន្តរប្រវេសន៍ និងការស្វែងរកការងារក្នុងស្រុកជូនពួកគេ និង (៣) ព័ត៌មានអំពីបណ្តាញគោលនយោបាយសកល (Global Policy Network)។
- អ្នកជំនាញការអង្គការ ILO ក្រោមគម្រោង Ship to Shore Rights South East Asia Programme ដើម្បីពិភាក្សាការងារ និងធ្វើបច្ចុប្បន្នភាព ពាក់ព័ន្ធនឹងការអនុវត្តគម្រោងកម្មវិធីសិទ្ធិពលករនេសាទនៅអាស៊ីអាគ្នេយ៍ និងកិច្ចសហប្រតិបត្តិការនៅកម្ពុជា ដែលគម្រោងនេះគឺមានកិច្ចសហការផ្សារភ្ជាប់ជាមួយមជ្ឈមណ្ឌលការងារខេត្តពោធិ៍សាត់ ដើម្បីពង្រីកវិសាលភាពនៃការផ្សព្វផ្សាយ និងបញ្ជ្រាបព័ត៌មានស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព លើកកម្ពស់សមត្ថភាពមន្ត្រី និងជួយរកការងារជូនពលករដែលវិលត្រលប់មកវិញ។
- អង្គការ WINROCK INTERNATIONAL ស្តីពីកិច្ចសហការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## ▪ថ្នាក់ក្រោមជាតិ

- **ខេត្តសៀមរាប** លេខាធិការដ្ឋាន គ.ខ.ប.ជ ក្រុមការងារទេសន្តរប្រវេសន៍ និងក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សស្រុកពួក បានទទួលប្រជុំពិភាក្សាការងារៈ **១**-និងផ្តល់កិច្ចសម្ភាសន៍ជាមួយក្រុមអ្នកស្រាវជ្រាវវាយតម្លៃរបស់ IJM ស្តីពីកិច្ចសហការលើការប្រយុទ្ធប្រឆាំងអំពើជួញដូរកម្លាំងពលកម្ម ចំនួន ០១លើក នៅរដ្ឋបាលសាលាខេត្ត។ **២**-ជាមួយអង្គការមូលនិធិA21 ស្តីពីការអនុវត្តផែនការសកម្មភាពឆ្នាំ ២០២២ លើការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន ០១លើក នៅរដ្ឋបាលសាលាខេត្ត។ **៣**-លើការអនុវត្តគម្រោងកិច្ចការពារជំនាន់ថ្មី ឬ Protection Plus ជាមួយអង្គការថ្លែនអន្តរជាតិ អង្គការសកម្មភាពដើម្បីកុមារ (APLE) អង្គការTPO អង្គការជំហានដំបូង និងអង្គការបណ្តាញសេវាទូរស័ព្ទកម្ពុជា ចំនួន ០១លើក តាមប្រព័ន្ធ Zoom។ **៤**-ជាមួយអង្គការជីវិតនៅកម្ពុជា អំពីការត្រៀមរៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព ស្តីពីវិធានការបង្វែរអនីតិជនជំទាស់នឹងច្បាប់ ចំនួន ០១លើក តាមប្រព័ន្ធ Zoom។ **៥**-ជាមួយអ្នកវាយតម្លៃគម្រោង ស្តីពីលើកកម្ពស់សិទ្ធិការងាររបស់ពលករចំណាកស្រុកកម្ពុជា ដែលមានជំនាញទាបនៅក្នុងប្រទេសថៃ ដែលអនុវត្តដោយអង្គការ We World ចំនួន ០១លើក នៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត។ **៦**-និងផ្តល់បទសម្ភាសន៍នៃការស្រាវជ្រាវ ស្តីពីការជួញដូរមនុស្សប្រទេសនៅក្នុងតំបន់មេគង្គប្រទេសកម្ពុជា ថៃ ឡាវ និងប្រទេសវៀតណាម(TIP) របស់គម្រោង JICA ។ **៧**-ជាមួយអ្នកវាយតម្លៃគម្រោងស្តីពី លើកកម្ពស់សិទ្ធិការងាររបស់ពលករចំណាកស្រុកកម្ពុជា ដែលមានជំនាញទាបនៅក្នុងប្រទេសថៃ ដែលអនុវត្តដោយអង្គការ We World។
- **ខេត្តបន្ទាយមានជ័យៈ**
  - លេខាធិការដ្ឋាន គ.ខ.ប.ជ បានផ្តល់បទសម្ភាសជាមួយក្រុមការងាររបស់ ក្រុមហ៊ុន RESEARCH និង Communication Group (RCG) សហការជាមួយអង្គការ IJM ដែលគោលបំណងនៃការជួបសម្ភាសន៍មានពីរៈ ១-សិក្សាស្វែងយល់ពីបទពិសោធន៍នៃដំណើររឿងក្តី និងការងារប្រយុទ្ធប្រឆាំងលើបទល្មើសជួញដូរពលកម្មក្នុងស្រុក និងឆ្លងដែន។ ២-ស្នើសុំមតិយោបល់ពីភាពខ្វះចន្លោះនៃការងារប្រយុទ្ធប្រឆាំងបទល្មើសខាងលើ និងអនុសាសន៍អំពីការធ្វើអោយប្រសើរឡើងនូវការងាររឿងក្តី ក៏ដូចជានីតិវិធីក្នុងកិច្ចសហការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរពលកម្ម ជាមួយស្ថាប័នពាក់ព័ន្ធនានា។

- ○ លោក **ណាង វុទ្ធី** អនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ បានជួបពិភាក្សាការងារជាមួយ អង្គការ JICA ស្តីពីគម្រោងពង្រឹងបណ្តាញក្នុងតំបន់សម្រាប់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅតាមតំបន់មេគង្គ (២០២១-២០២៤)។
- **ខេត្តស្វាយរៀង៖** លោកជំទាវ **ឯក សុវណ្ណភារៈ** អភិបាលរង និងជាអនុប្រធានអចិន្ត្រៃយ៍គ.ខ.ប.ជ បាន៖
  - ○ ជួបប្រជុំពិភាក្សាការងារ ជាមួយក្រុមការងារស្ថានទូតសហរដ្ឋអាមេរិក លោក **ចូណាថាន អាដាម** ប្រធានផ្នែកនយោបាយ និងលោក ស៊ុយ ហ៊ាមខេមរា អ្នកជំនាញនយោបាយ ពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងពលកម្មកុមារ។
  - ○ ប្រជុំពិភាក្សាការងារជាមួយអង្គការជំនួយផ្លូវច្បាប់ ដល់កុមារ និងស្ត្រី ពាក់ព័ន្ធការអនុវត្តគម្រោង "ការពង្រឹងសិទ្ធិទទួលបានការអប់រំ និងការងារ តាមរយៈការចូលរួមរបស់សហគមន៍ ក្នុងគោលបំណង ដើម្បីចូលរួមទប់ស្កាត់អំពើជួញដូរមនុស្ស និងផ្តល់សេវាគាំទ្រសម្រាប់ពលករ។"
- **ខេត្តតាកែវ៖** លោកស្រីអនុប្រធានអចិន្ត្រៃយ៍គ.ខ.ប.ជ បានជួបពិភាក្សាការងារជាមួយលោកជំទាវ **ទូច សារ៉ុម** រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា ស្តីពីការបញ្ជ្រាបការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទាំងពុទ្ធចក្រ និងអាណាចក្រ នៅសាលប្រជុំក្រសួងកិច្ចការនារី។
- **ខេត្តកោះកុង៖** លោកស្រី **អ៊ុន សុគន្ធីតា** នាយករងរដ្ឋបាល និងជាអនុប្រធានលេខាធិការដ្ឋាន បានជួបពីភាក្សាជាមួយអង្គការវីនរ៉ក់អន្តរជាតិ ស្តីពីការកំណត់ស្រុកគោលដៅដើម្បីអនុវត្តគម្រោងប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស នៅក្នុងខេត្តកោះកុង ០១លើក។
- **ខេត្តត្បូងឃ្មុំ៖** លោកជំទាវ **នី ចាន់ធីតា** ប្រធានលេខាធិការដ្ឋាន បានដឹកនាំក្រុមការងារជំនាញទាំង ០៦ សមាជិកលេខាធិការដ្ឋានថ្នាក់ខេត្ត និងអង្គការសង្គមស៊ីវិល ជួបពិភាក្សាការងារជាមួយអង្គការជំនួយ ផ្លូវច្បាប់ដល់កុមារនិងស្ត្រី លើគម្រោងស្តីពី ការជំរុញឱ្យទទួលបានភាពយុត្តិធម៌ និងសេវាគាំទ្រដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស មានអ្នកចូលរួម ២០រូប។
- **ខេត្តកំពង់ចាម៖** លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តកំពង់ចាម បានទទួលជួបពិភាក្សាការងារជាមួយ អង្គការជំនួយផ្លូវច្បាប់ដល់ស្ត្រី ដោយបានលើកយកបញ្ហា របស់ប្រជាពលរដ្ឋចំណាកស្រុក មិនស្របច្បាប់ ការដែលទៅធ្វើការងារជាពលករតាមរដូវកាល នៅប្រទេសកូរ៉េខាងត្បូង។

## គ. ការងារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ **៥២៤**លើក មានអ្នកចូលរួមសរុប **៣.៨៧៨**នាក់ (ស្រី **១.២៣១**នាក់) ក្នុងនោះមាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន **១៧១**លើក ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន **២៧**លើក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា **១១២**លើក ក្រសួងទេសចរណ៍ចំនួន **០៣**លើក អង្គការរតនៈអ៊ីនធើណេសិនណល **១០**លើក និងលេខាធិការដ្ឋានរាជធានី ខេត្ត ចំនួន **២០១**លើក។**(ឧបសម្ព័ន្ធ១)**

# IV. ការសន្និដ្ឋានវាយតម្លៃ

## ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ **០៤ចំណុច** និងវិធានការ **០៦ចំណុច** របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់ គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

- យើងមានច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួង ស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

## ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖

- ក្រសួង ស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ថ្វីត្បិតតែមានយន្តការក្នុងកិច្ចសហប្រតិបត្តិការគ្នា តែកិច្ចសហការមួយចំនួននៅមិនទាន់បានល្អនៅឡើយ។
- មន្ត្រីទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សមួយចំនួន មានការផ្លាស់ប្តូរ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំង និងរំលេចឱ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

## គ. សំណូមពរ

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនីមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឱ្យលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឱ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

## ឃ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឱ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។

- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V. ទិសដៅអនុវត្តបន្តឆមាសទី២ ឆ្នាំ ២០២២

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោមៈ

### ក.ការងារច្បាប់ គោលនយោបាយ និងកិច្ចសហប្រតិបត្តិការ

១.បន្តរៀបចំគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលជាតម្រូវការចាំបាច់សម្រាប់បម្រើដល់ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទាំងក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ ។

២.ធ្វើបច្ចុប្បន្នភាពសៀវភៅ គោលការណ៍ណែនាំស្តីពី បែបបទនិងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប។

៣.គាំទ្រ និងសហការជាមួយក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ និងក្រសួងកិច្ចការនារី ដើម្បីបន្តពិគ្រោះយោបល់ និងពិនិត្យឡើងវិញខ្លឹមសារសេចក្តីព្រាងច្បាប់ ស្តីពីអំពើពពោះជំនួស។

៤.ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសកិច្ចសហការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ ក្នុងវិស័យព្រហ្មទណ្ឌជាមួយប្រទេសពាក់ព័ន្ធ។

៥.បន្តជំរុញការអនុវត្តអនុស្សរណៈ និងកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី ជាមួយបណ្តាប្រទេស និងដៃគូពាក់ព័ន្ធដែលបានចុះហត្ថលេខារួចហើយ ដើម្បីបង្កើនប្រសិទ្ធភាព និងប្រសិទ្ធផល។

៦.ត្រៀមចុះហត្ថលេខាលើស្តង់ដានៃនីតិវិធីប្រតិបត្តិ ស្តីពីកិច្ចសហការក្នុងការអនុវត្តច្បាប់ រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្ស នៃព្រះរាជាណាចក្រថៃ។

៧.ត្រៀមប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការគោលនយោបាយជាតិ ស្តីពីសុខភាពជនទេសន្តរប្រវេសន៍ របស់ក្រសួងសុខាភិបាល។

៨.រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ ដើម្បីកសាងបទដ្ឋានគតិយុត្តនានា សម្រាប់ការពារសិទ្ធិ សុវត្ថិភាព ផលប្រយោជន៍ និងសេចក្តីថ្លៃថ្នូររបស់ពលករទេសន្តរប្រវេសន៍ក្នុងវិស័យនេសាទសមុទ្រ។

៩.ត្រៀមកិច្ចប្រជុំបួនប្រទេស កម្ពុជា ឡាវ វៀតណាម មីយ៉ាន់ម៉ា ក្នុងការពង្រឹងកិច្ចសហការ ការពារ និងបង្ការ ទប់ស្កាត់ ការនាំមនុស្សឆ្លងដែនខុសច្បាប់ ជាពិសេសស្ត្រី និងកុមារ ក៏ដូចជាទារក។

១០.ត្រៀមបន្តចុះហត្ថលេខាអនុស្សរណៈ/កិច្ចព្រមព្រៀងសហប្រតិបត្តិការ ជាមួយដៃគូពាក់ព័ន្ធ។

១១.បន្តលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ទាំងក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ ដើម្បីពង្រឹងការអនុវត្តវិធានការច្បាប់ វិធានការបង្ការទប់ស្កាត់ និងវិធានការសង្គ្រោះ និងការពារជនរងគ្រោះទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

១២.បន្តលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ទាំងក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ ដើម្បីពង្រឹងការអនុវត្តវិធានការច្បាប់ វិធានការបង្ការទប់ស្កាត់ និងវិធានការសង្គ្រោះ និងការពារជនរងគ្រោះទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

១៣.បន្តពង្រឹងយន្តការដឹកនាំបញ្ជាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពទាំងលើការងារផ្សព្វផ្សាយអប់រំ និងការបោត់តាំងអនុវត្តច្បាប់ ព្រមទាំងជំរុញការតាមដានត្រួតពិនិត្យ និង

កែលម្អជាប្រចាំចំពោះកិច្ចប្រតិបត្តិការរបស់មន្ត្រីអនុវត្តច្បាប់ សំដៅជំរុញឱ្យការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សកាន់តែទទួលបានប្រសិទ្ធផលខ្ពស់ ។

## ខ. ការងារបង្ការ ទប់ស្កាត់

១.បន្តសហការជាមួយអង្គការសកម្មភាពដើម្បីកុមារ(APLE) រៀបចំយុទ្ធនាការ «គាំទ្រទិវាអន្តរជាតិដើម្បីសុវត្ថិភាពអ៊ីនធឺណិត និងលើកកម្ពស់សីលធម៌ ដើម្បីសុវត្ថិភាពសង្គម»។

២.សហការជាមួយអង្គការសកម្មភាពដើម្បីកុមារ(APLE) រៀបចំសិក្ខាសាលាច្រកចេញចូលតែមួយ ស្តីពី «សេវាកម្មកុមារ»។

៣.ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធ បន្តបើកវគ្គបណ្តុះបណ្តាលសៀវភៅសិក្សាអប់រំស្តីពី «ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំបង្រៀន» ដល់គ្រូឧទ្ទេសក៍ថ្នាក់ជាតិ គ្រូឧទ្ទេសក៍គរុកោសល្យភូមិភាគ និងគ្រូបង្គោល តាមសាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ នៅទូទាំងប្រទេស និងតាមដានការអនុវត្តកម្មវិធីសិក្សាគ្រប់កម្រិតខាងលើ។

៤.ក្រសួងទេសចរណ៍ បន្តការរៀបចំសិក្ខាសាលា ស្តីពីសុវត្ថិភាពកុមារក្នុងវិស័យទេចរណ៍ដល់ម្ចាស់មូលដ្ឋានអាជីវកម្ម សេវាកម្មទេសចរណ៍តាមបណ្តារាជធានី-ខេត្ត។

៥.សហការជាមួយនិយ័តករទូរគមនាគមន៍កម្ពុជា(TRC) ធ្វើការផ្សព្វផ្សាយសារអប់រំ ដល់ប្រជាពលរដ្ឋ តាមរយៈទូរស័ព្ទចល័ត នៅថ្ងៃទិវាជាតិពាក់ព័ន្ធ។

៦.អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សហការជាមួយទីភ្នាក់ងារជាតិមុខរបរ និងការងារ(NEA) ដើម្បីជំរុញ និងពង្រីកការផ្សព្វផ្សាយអំពីឱកាសការងារឱ្យកាន់តែទូលំទូលាយនៅតាមសហគមន៍ ជាពិសេសសហគមន៍ ដែលងាយរងគ្រោះ រួមទាំងពលករទេសន្តប្រវេសន៍ដែលវិលត្រឡប់។

៧.សហការជាមួយ រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបង្កើតនីតិវិធីងាយស្រួលក្នុងការផ្សារភ្ជាប់ទំនាក់ទំនង និងការទទួលបានការប្រឹក្សាយោបល់ពីទីភ្នាក់ងារជាតិមុខរបរ និងការងារ និងក្រសួង ស្ថាប័នពាក់ព័ន្ធ អំពីជម្រើសការងារ ឬមុខរបរ និងការបណ្តុះបណ្តាលជំនាញបច្ចេកទេសផ្សេងៗសម្រាប់ក្រុមជនងាយរងគ្រោះ ជាពិសេស ពលករទេសន្តប្រវេសន៍ដែលវិលត្រឡប់ពីបរទេស។

៨.បន្តជំរុញការគ្រប់គ្រង និងធ្វើអធិការកិច្ចទីភ្នាក់ងារជ្រើសរើសឯកជន ដើម្បីធានាការអនុវត្តគោលនយោបាយ និងច្បាប់ពាក់ព័ន្ធនឹងតួនាទី និងការទទួលខុសត្រូវរបស់ទីភ្នាក់ងារ ក្នុងការការពារសុវត្ថិភាព និងផ្តល់ភាពងាយស្រួលដល់ពលករក្នុងការធ្វើទេសន្តប្រវេសន៍ការងារ។

៩.បន្តរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ និងវេទិកាជាតិអន្តរសាសនានៅកម្ពុជា ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

១០.បន្តសហការជាមួយអង្គការសហប្រជាជាតិ (IOM, WHO, UNFPA, UNICEF) និងដៃគូផ្សេងៗទៀត ដើម្បីរៀបចំកម្មវិធី ឆ្លើយតបទៅនឹងផលប៉ះពាល់លើសុខភាព និងជីវភាពពលករទេសន្តប្រវេសន៍ និងគ្រួសារ ក្នុងស្ថានភាពនៃការរាតត្បាតដោយជំងឺកូវីដ-១៩ និងគ្រោះមហន្តរាយផ្សេងៗទៀត។

១១.បន្តចូលរួមយ៉ាងសកម្មក្នុងការអនុវត្ត គោលនយោបាយ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ការផ្សព្វផ្សាយអំពីការបង្ការ ទប់ស្កាត់ ការឆ្លង និងចម្លងជំងឺកូវីដ-១៩ និងផលប៉ះពាល់ ព្រមទាំងចុះតាមដានការអនុវត្តគោលនយោបាយនានារបស់រាជរដ្ឋាភិបាល នៅថ្នាក់ក្រោមជាតិ។

១២.បន្តលើកកម្ពស់ការងារផ្សព្វផ្សាយច្បាប់ គោលនយោបាយ និងពង្រីកការអប់រំតាមគ្រប់រូបភាព ដើម្បីលើកកម្ពស់ការយល់ដឹងឱ្យបានទូលំទូលាយ អំពីរាល់ទម្រង់នៃអំពើជួញដូរមនុស្ស ទំនាក់ទំនងរវាងទេសន្តប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋ ជាពិសេសស្រទាប់យុវវ័យក្នុងនិងក្រៅសាលារៀន និងជនងាយរងគ្រោះដទៃទៀត។

១៣.បង្កើនការចុះធ្វើអធិការកិច្ច ជាពិសេស អធិការកិច្ចដោយមិនជូនដំណឹងជាមុន ដើម្បីកំណត់រកអំពើកេងប្រវ័ញ្ចផ្សេងៗ និងមានវិធានការក្នុងប្រភេទការងារដែលមានភាពរងគ្រោះខ្ពស់ ដូចជានៅតាមទីភ្នាក់ងារជ្រើសរើសពលករឯកជន រោងចក្រសហគ្រាស សហគ្រាសឡឥដ្ឋ កសិដ្ឋាន ផ្ទះសំណាក់ សណ្ឋាគារ កន្លែងសេវាកម្សាន្ត ជាដើម។

១៤.លើកកម្ពស់ការគ្រប់គ្រងទីភ្នាក់ងារជ្រើសរើសពលករ និងការអនុវត្តក្រមសីលធម៌ របស់ទីភ្នាក់ងារ និងកាត់បន្ថយការយកថ្លៃឈ្នួលពីពលករ ក្នុងនីតិវិធីនៃការជ្រើសរើសពលករទេសន្តប្រវេសន៍។
១៥.បន្ត និងជំរុញរៀបចំផែនការអនុវត្តគោលបំណងអាទិភាព GCM និងអនុសញ្ញាអាស៊ាន។

## គ. ការងារអនុវត្តច្បាប់ និងយុត្តិធម៌ព្រហ្មទណ្ឌ

១.បន្តពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ និងមន្ត្រីជួរមុខក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
២.បន្តស៊ើបអង្កេត ស្រាវជ្រាវ បង្ក្រាប និងផ្តន្ទាទោស បទល្មើសពាក់ព័ន្ធអំពើជួញដូរមនុស្ស ក្នុង និងក្រៅប្រទេស ជាពិសេសបទល្មើសថ្មី ដែលបង្កដោយជនបរទេស។
៣.បន្តពង្រឹងកិច្ចសហការរវាងមន្ត្រីនគរបាលយុត្តិធម៌ និងស្ថាប័នអយ្យការ ក្នុងការអនុវត្តនីតិវិធីស៊ើបអង្កេតប្រមូលភស្តុតាង ដើម្បីដាក់បន្ទុកជនល្មើសជួញដូរមនុស្ស។
៤.បន្តពង្រឹងកិច្ចសហការជាមួយសមត្ថកិច្ចប្រទេសពាក់ព័ន្ធ ដើម្បីជំរុញការងារអនុវត្តច្បាប់ និងយុត្តិធម៌ព្រហ្មទណ្ឌ ក្នុងការបង្ក្រាបបទល្មើសជួញដូរមនុស្សឆ្លងដែន។
៥.ជំរុញការអនុវត្តនីតិវិធី នៃការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ។

## ឃ. ការងារការពារជនរងគ្រោះ

១.ជំរុញប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យពលករ ជាពិសេស ពលករដែលមិនមានឯកសារស្របច្បាប់ នៅក្នុងរដ្ឋនៃទេសន្តប្រវេសន៍ ដើម្បីធ្វើជាមូលដ្ឋានក្នុងការរៀបចំគោលនយោបាយ និងវិធានការសម្រាប់ការគ្រប់គ្រងលំហូរទេសន្តប្រវេសន៍ និងការផ្តល់សេវាឲ្យបានសមស្រប ។
២.បន្តពង្រឹងយន្តការសម្រាប់ការទទួលពលករ ការគ្រប់គ្រង និងដំណើរការមណ្ឌលទទួលពលករ កំរៀង ខេត្តបាត់ដំបង ដោយមានកិច្ចសហការពីបណ្តាក្រសួង ស្ថាប័ន មន្ទីរ អង្គភាពពាក់ព័ន្ធ និងអង្គការដៃគូក្នុងការផ្តល់សេវា។
៣.រៀបចំសិក្ខាសាលាថ្នាក់ជាតិ ស្តីពីកិច្ចការពារកុមារ ក្នុងទេសន្តប្រវេសន៍ ពីអំពើជួញដូរមនុស្ស និងការរំលោភបំពាន ។
៤.ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បន្តរៀបចំវគ្គបណ្តុះបណ្តាលៈ
- គោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស។
- គោលការណ៍ណែនាំស្តីពី «បែបបទ និងនីតិវិធី នៃការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប» ដល់មន្ត្រីជួរមុខ។

៥.ធ្វើបច្ចុប្បន្នភាពលើនីតិវិធីប្រតិបត្តិបទដ្ឋាន(SOPs) ស្តីពីនីតិវិធីប្រគល់ និងទទួលជនរងគ្រោះដោយសារការជួញដូរមនុស្ស រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម។
៦. អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បន្តកិច្ចសហប្រតិបត្តិការជាមួយៈ
- ក្រសួងសុខាភិបាល ក្នុងការជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស ឲ្យទទួលបានសេវាពិនិត្យសុខភាព និងការព្យាបាលសង្គ្រោះបន្ទាន់ដោយឥតគិតថ្លៃ នៅតាមមជ្ឈមណ្ឌលសុខភាព និងមន្ទីរពេទ្យរបស់រដ្ឋ។
- ស្ថានទូត និងកុងស៊ុល នៅក្រៅប្រទេស(តាមរយៈក្រសួងការបរទេស) ដើម្បីជួយដល់ជនរងគ្រោះ និងសម្រួលដល់ដំណើរការមាតុភូមិនិវត្តន៍មកប្រទេសកម្ពុជាឱ្យបានឆាប់រហ័ស និងមានសុវត្ថិភាព។
- ក្រសួងស្ថាប័ន និងអង្គការដៃគូ ដែលធ្វើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

៧.បន្តចុះអធិការកិច្ចមជ្ឈមណ្ឌលរបស់អង្គការដែលបានចុះកិច្ចព្រមព្រៀងជាមួយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។
៨.ពិនិត្យលទ្ធភាព ដើម្បីបង្កើតមជ្ឈមណ្ឌលស្តារនីតិសម្បទាជនរងគ្រោះជារបស់រដ្ឋ។
៩.គាំទ្រក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្នុងការបណ្តុះបណ្តាលមន្ត្រីពាក់ព័ន្ធនៅ ក្នុងស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសគោលដៅ អំពីគោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប។

១០.រៀបចំឧបករណ៍វាយតម្លៃអំពីភាពប្រឈម នៃមេរៀន ស្តីពី«ការអនុវត្តនីតិវិធីនៃការកំណត់អត្តសញ្ញាណ បឋម ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប» ក្នុងខេត្តដែលបានបណ្តុះបណ្តាលរួចហើយ។

១១.រៀបចំយន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃការផ្តល់សេវាដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅតាមមណ្ឌល និងនៅតាមសហគមន៍។

**ខ. ការងារពង្រឹងសមត្ថភាព និងការតាមដានត្រួតពិនិត្យ**

១.ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធ ដល់មន្ត្រីទទួលបន្ទុកអនុវត្តថ្នាក់ក្រោមជាតិ លើការងារលេខាធិការដ្ឋាន ការងាររបាយការណ៍ ការកសាងផែនការ និងការងារត្រួតពិនិត្យ វាយតម្លៃ។

២.បន្តធ្វើការប៉ាន់ប្រមាណ និងវាយតម្លៃពាក់កណ្តាលអាណត្តិ ទៅលើការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ៥ឆ្នាំ(២០១៩-២០២៣) ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

៣.អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ គាំទ្រ និងសហការជាមួយក្រសួងយុត្តិធម៌ អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីរៀបចំយន្តការប្រមូលទិន្នន័យថ្នាក់ជាតិ ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ជាពិសេសទិន្នន័យនៃការអនុវត្តច្បាប់ ការផ្តន្ទាទោស និងការងារការពារជនរងគ្រោះឱ្យមានសង្គតិភាព។

៤.គាំទ្រពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធនឹងការងារគ្រប់គ្រង គ្រប់ផ្នែក ដល់មន្ត្រីជំនាញក្នុងក្រុមការងារ និងលេខាធិការដ្ឋានរាជធានី ខេត្ត ដើម្បីពង្រឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

៥.បន្តធ្វើសេចក្តីសម្រេចកែសម្រួលសមាសភាពក្រុមការងារអន្តរក្រសួង ស្ថាប័ន និងគណៈកម្មាធិការរាជធានី ខេត្ត។

៦.រៀបចំប្រព័ន្ធប្រមូល ចងក្រង និងចែកចាយទិន្នន័យ តាមផ្នែកពាក់ព័ន្ធសំខាន់ៗ។

ថ្ងៃពុធ ១១រោច ខែភទ្របទ ឆ្នាំ ខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២

**ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

**សម្តេចក្រឡាហោម ស ខេង**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន
-សមាជិកក្រុមការងារ គ.ជ.ប.ជ
-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**"ដើម្បីជូនជ្រាប"**

-ឯកសារ កាលប្បវត្តិ